សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
**Université Royale de Droit et des Sciences Economiques**
**Royal University of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# បញ្ហាចោទសុំកូនក្នុងប្រទេស

ស្រាវជ្រាវពីថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៧ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧


តាក់តែងឡើងដោយ

និស្សិតឈ្មោះ **មនោ កែវគតិយុត្តិ**

សាស្ត្រាចារ្យណែនាំ

**អ្នកស្រី ស្រី វណ្ណធី**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៧

ឆ្នាំចូលសិក្សា ២០១៣

ឆ្នាំសរសេរសារណា ២០១៧

# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **មនោ កែវគតិយុត្តិ** ជានិស្សិតបញ្ចប់ថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រឆ្នាំទី៤ ជំនាន់ទី១៧ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចក្នុងឆ្នាំសិក្សា ២០១៦-២០១៧។

ខ្ញុំបាទពិតជាមានសេចក្ដីសោមនស្សយ៉ាងកក់ក្ដៅជាទីបំផុត ដោយមានឱកាសថ្លែងអំណរគុណដល់លោកឪពុក **តា មនោ** និងអ្នកម្ដាយ **សេង សុខា** ដែលលោកទាំងទ្វេ ជាអ្នកមានគុណយ៉ាងលើសលុប គ្មានថ្ងៃណាកូនបំភ្លេចបានឡើយ។

ពួកគាត់ បានផ្ដល់កំណើតដល់កូន និងចិញ្ចឹមបីបាច់ថែរក្សាកូនយ៉ាងយកចិត្តទុកដាក់បំផុតប្រកបដោយព្រហ្មវិហារធម៌។ លើសពីនេះ លោកបានពុះពារគ្រប់ឧបសគ្គ ដើម្បីអនាគតកូន មិនថាយប់ ឬថ្ងៃឡើយ ដោយខិតខំរកប្រាក់ ទោះបីថាគ្មានមុខងារខ្ពស់ក្នុងសង្គមនឹងគេក៏ដោយ។ លោកមិនត្រឹមតែបានផ្ដល់នូវក្ដីស្រលាញ់តែម៉្យាងទេ លោកថែមទាំងបញ្ជូនកូនឲ្យសិក្សា អប់រំ តាំងពីថ្នាក់មតេយ្យរហូតបញ្ចប់ថ្នាក់បរិញ្ញាប័ត្រប្រកបដោយជោគជ័យ ដោយផ្ដល់ទាំងសំភារៈ និងស្មារតី។ រាល់ដំបូន្មានល្អៗរបស់អ្នកមានគុណ កន្លងមកកូនមិនដែលភ្លេចម្ដងណាឡើយ កូនតែងតែចងចាំជានិច្ច និងពិតជាមានតម្លៃយ៉ាងធំធេង។

ខ្ញុំបាទ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង និង លោកគ្រូ អ្នកគ្រូ** ដែលជាសាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ទាំងអស់ដែលបានខិតខំអស់កំលាំងកាយចិត្តក្នុងការផ្ដល់នូវ ចំណេះដឹងដល់និស្សិតគ្រប់រូប ពិសេសរូបខ្ញុំបាទរហូតដល់ចប់មហាវិទ្យាល័យនីតិសាស្ត្រនេះ។ ជាពិសេស ក៏មិនភ្លេចថ្លែងអំណរគុណផងដែរ ចំពោះអ្នកគ្រូ **ស្រី វណ្ណធី** ដែលអ្នកគ្រូមិនត្រឹមតែបានបង្ហាត់បង្ហាញដល់ខ្ញុំកន្លងមកនោះទេ ហើយថែមទាំងណែនាំសារណាបញ្ចប់ការសិក្សាលើប្រធានបទមួយនេះទៀត។ អ្នកគ្រូបានផ្ដល់នូវដំបូន្មានល្អៗ ក៏ដូចជាគន្លឹះក្នុងការស្វែងរកឯកសារវិធីសាស្ត្រក្នុងការចងក្រងសារណា និងការកែលម្អឲ្យកាន់តែល្អថែមទៀត។

ជាចុងបញ្ចប់ ខ្ញុំបាទសូមថ្លែងអំណរគុណជាថ្មីម្ដងទៀត និងសូមប្រសិទ្ធិពរជ័យដល់លោកអ្នកមានគុណទាំងទ្វេ ឯកឧត្តមសាកលវិទ្យាធិការ វិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្ត្រាចារ្យទាំងអស់ឲ្យជួបប្រទះតែសេចក្ដីសុខ និងសុខភាពល្អបរិបូរជានិរន្តន៍។

## អារម្ភកថា

សារណាបញ្ចប់ឆ្នាំសិក្សា គឺជាគោលបំណងខ្ញុំបាទតាំងពីឆ្នាំទីមួយមក។ ដោយយល់ឃើញថាប្រធានបទ **បញ្ហាចោទសុំកូនក្នុងប្រទេស** ជាប្រធានបទមួយដែលគួរឲ្យមានការចាប់អារម្មណ៍គ្រប់មជ្ឈដ្ឋានមិនថារដ្ឋាភិបាលដែលខិតខំបង្កើតច្បាប់នានា ដើម្បីការធានាឧត្តមប្រយោជន៍ និងកិច្ចការពារកុមារ គឺជាកាតព្វកិច្ចរបស់យើងទាំងអស់គ្នាដែលត្រូវគិតគូរឲ្យកុមារ មានការរីកចម្រើន និងអភិវឌ្ឍន៍នៅក្នុងគ្រួសារមួយដ៏ល្អប្រកបដោយភាពកក់ក្ដៅ និងគ្មានការបំពានសិទ្ធិ។ ផ្ទុយមកវិញ បើការទុកដាក់កុមារនៅក្នុងគ្រួសារមួយ ដែលមិនមានលក្ខណៈសមស្រប វានឹងធ្វើអោយប៉ះពាល់ដល់សិទ្ធិ និងអត្ថប្រយោជន៍របស់កុមារ ដែលជាកត្តានាំអោយជះឥទ្ធិពលដល់សង្គមជាតិនាពេលអនាគត ព្រោះថាកុមារ គឺជាសសរទ្រូងសម្រាប់ស្នងប្រទេសជាតិ។

ការលើកយកប្រធានបទនេះឡើង គឺពឹងផ្អែកលើចំណេះដឹងផ្ទាល់ខ្លួន បូករួមជាមួយឯកសារជាមូលដ្ឋានដទៃទៀតជាច្រើន ដើម្បីស្រាយចម្ងល់ដល់ខ្លួនឯង និងបំភ្លឺផ្លូវដល់បងប្អូននិស្សិត ក៏ដូចជា ប្រជាពលរដ្ឋខ្មែរ ដែលចង់យល់ច្បាស់ពីបញ្ហាសុំកូនស្របពេលដែលពួកគាត់មានបំណងសុំកូន និងធ្វើយ៉ាងណាលើកស្ទួយជីវិតដ៏ទន់ខ្សោយរបស់កុមារដែលជាកូនសុំ បានទទួលជីវិតថ្មីមួយដ៏ត្រចះត្រចង់។

ក្នុងនាមខ្ញុំបាទជាអ្នកចងក្រងឯកសារនេះ សូមធ្វើការអភ័យទោសចំពោះកំហុសឆ្គងទាំងឡាយណាដែលកើតឡើងដោយអចេតនា ទាំងអក្ខរាវិរុទ្ធក្ដី ទាំងការប្រើពាក្យពេចន៍ខ្លឹមសារក្ដី ឬអត្ថន័យក្នុងអត្ថបទក្ដី។ ទោះបីជាមានការផ្ទិតផ្ទង់ ផ្ទៀងផ្ទាត់ជាច្រើនដង ឬយកចិត្តទុកដាក់ក្ដី តែកំហុសបន្តិចបន្តួចនោះនៅតែកើតមានដោយអចេតនាជៀសមិនផុតឡើយ អាស្រ័យហេតុនេះ សូមលោកទាំងអស់មេត្តាអធ្យាស្រ័យ និងជួយកែតំរូវដើម្បីឲ្យស្នាដៃមួយនេះបានល្អប្រសើរជាងនេះ ហើយក៏ សំរាប់ទុកជាបទពិសោធន៍ទៅថ្ងៃក្រោយផងដែរ។ ជាចុងក្រោយ ខ្ញុំបាទមានតែពាក្យជូនពរដល់ លោកសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ ប្រិយមិត្តអ្នកអាន មិត្តនិស្សិតទាំងឡាយ ដែលបានចំណាយពេលវេលាដ៏មានតម្លៃយកចិត្តទុកដាក់លើប្រធានបទមួយនេះ និង សូមជូនពរនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា


**ទំព័រ**

**សេចក្តីផ្តើម......01**

**ជំពូកទី១**

**ទស្សនៈទានទូទៅនៃសុំកូន**

**ផ្នែកទី១ ៖ ផ្នត់គំនិតគោលនៃសុំកូន......0៣**

**១.១. នីតិវិធីច្បាប់......0៤**

១.១.១. ការដាក់ពាក្យសុំ......**0៥**

១.១.២. ការដកពាក្យសុំ......**0៥**

**១.២. ការវិវត្តន៍នៃសង្គម......0៥**

**១.៣. ស្ថានភាពគ្រួសារ......0៦**

**ផ្នែកទី២ ៖ សារៈប្រយោជន៍នៃសុំកូន......0៧**

**២.១. ចំពោះសង្គម......0៧**

**២.២ ចំពោះបុគ្គល......0៨**

២.២.១. ចំពោះឪពុកម្តាយចិញ្ចឹម......**0៨**

២.២.២. ចំពោះកូនចិញ្ចឹម......**0៨**

**ជំពូកទី២**

**លក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់នៃសុំកូន**

**ផ្នែកទី១ ៖ ចំពោះសុំកូនពេញលេញ......0៩**

**១.១. កត្តាបុគ្គល......១០**

១.១.១. លក្ខខណ្ឌចំពោះឪពុកម្តាយចិញ្ចឹម......**១០**

១.១.១.១. អាយុ ...11 ១១
១.១.១.២. ស្ថានភាពគ្រួសារ ... ១១
១.១.១.៣. ជីវភាព ... ១១
១.១.២. លក្ខខណ្ឌចំពោះកូនសុំពេញលេញ ... ១២
១.១.២.១. អាយុ ... ១២
១.១.២.២. ស្ថានភាពរបស់កូន ... ១៣
១.១.៣. លក្ខខណ្ឌផ្សេងៗទៀត ... ១៣
**១.២. កត្តាចិត្តសាស្ត្រ និងហិរញ្ញវត្ថុ** ... ១៣
១.២.១. កត្តាចិត្តសាស្ត្រ ... ១៣
១.២.២. កត្តាហិរញ្ញវត្ថុ ... ១៤
**ផ្នែកទី២ ៖ ចំពោះសុំកូនធម៌តា** ... ១៥
**២.១. ចំពោះឪពុកម្តាយចិញ្ចឹម** ... ១៥
២.១.១. អាយុ ... ១៥
២.១.២. ស្ថានភាព ... ១៦
**២.២. ចំពោះកូនសុំ** ... ១៦
២.២.១. អាយុ ... ១៦
២.២.២. ស្ថានភាពរបស់កូន ... ១៦

## ជំពូកទី៣

## អានុភាព និងបញ្ហាចោទជុំវិញសុំកូន

**ផ្នែកទី១ ៖ អានុភាពទូទៅនៃសុំកូន** ... ២០

**១.១. ចំពោះកូនស្មុំពេញលេញ** ..................................................... ២០

១.១.១. ការបញ្ចប់នូវញាតិភាពជាមួយនឹងឪពុកម្ដាយបង្កើត ..................... ២០

១.១.២. ការបង្កើតញាតិភាពជាមួយនឹងឪពុកម្ដាយចិញ្ចឹម ......................... ២២

**១.២. ចំពោះកូនស្មុំធម្មតា** ..................................................... ២៤

១.២.១. ការបន្តញាតិភាពជាមួយឪពុកម្ដាយបង្កើត ..................................... ២៤

១.២.២. ការបង្កើតញាតិភាពជាមួយឪពុកម្ដាយចិញ្ចឹម ................................. ២៥

**ផ្នែកទី២ ៖ បញ្ហាចោទចំពោះកូនស្មុំ** ..................................................... ២៥

**២.១. ការកាត់កាល់** ..................................................... ២៥

២.១.១. ចំពោះស្មុំកូនពេញលេញ ..................................................... ២៦

២.១.១.១. មូលហេតុ និងការវិនិច្ឆ័យការកាត់កាល់... .................................. ២៦

២.១.១.២. លក្ខខណ្ឌនៃការកាត់កាល់ស្មុំកូនពេញលេញ ................................ ២៦

២.១.១.៣. អានុភាពនៃការកាត់កាល់ស្មុំកូនពេញលេញ ................................. ២៧

២.១.២. ចំពោះស្មុំកូនធម្មតា ..................................................... ២៨

២.១.២.១. មូលហេតុ និងការវិនិច្ឆ័យការកាត់កាល់ ..................................... ២៨

២.១.២.២. ពាក្យសុំឲ្យកាត់កាល់ស្មុំកូនធម្មតា ............................................ ២៩

២.១.២.៣. លក្ខខណ្ឌនៃការកាត់កាល់ស្មុំកូនធម្មតា ....................................... ២៩

២.១.២.៤. អានុភាពនៃការកាត់កាល់ស្មុំកូនធម្មតា ....................................... ៣០

**២.២. ការបោះបង់កូនស្មុំចោល** ..................................................... ៣០

២.២.១. ឪពុកម្ដាយស្មុំ ..................................................... ៣០

២.២.២. កូនស្មុំ ..................................................... ៣០

ផ្នែកទី៣ ៖ ទោសទណ្ឌ ........................................................................................................៣០
សេចក្តីសន្និដ្ឋាន......................................................................................................... ..៣២
អនុសាសន៍ .......................................................................................................... ...៣៤
ឯកសារយោង
ឧបសម្ព័ន្ធ

# សេចក្តីផ្តើម

បច្ចុប្បន្នសិទ្ធិរបស់កុមារត្រូវបានរាជរដ្ឋាភិបាលកម្ពុជាយកចិត្តទុកដាក់យ៉ាងខ្លាំង ដោយរដ្ឋគឺជាអ្នករក្សាការពារសិទ្ធិរបស់កុមារដែលមានចែងក្នុងអនុសញ្ញា ស្តីពីសិទ្ធិរបស់កុមារ និងអនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ ដែលព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នកាលពីថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩២ ដោយសារតែមានការរីករាលដាលនៃការជួញដូរ និងការកេងប្រវ័ញ្ចលើមនុស្សស្របពេលនោះផងដែរ ការសុំកូនមកចិញ្ចឹមគឺមានការកើនឡើងគួរឲ្យកត់សម្គាល់។

ការសុំកូនត្រូវបានផ្តល់សិទ្ធិដល់កុមារឲ្យទទួលបានការថែទាំជំនួសក្នុងករណី ឪពុកម្តាយបង្កើតគ្មានលទ្ធភាព ឬជាកូនកំព្រាដើម្បីផ្តល់គ្រួសារអចិន្ត្រៃយ៍ និងផ្តល់បរិយាកាសល្អនៅក្នុងគ្រួសារថ្មីដល់កុមារ។ លើសពីនេះទៅទៀត គឺគិតពីឧត្តមប្រយោជន៍ដែលនឹងផ្តល់ឲ្យកុមារនូវសិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានការអប់រំ ជាពិសេសគឺសិទ្ធិទទួលបានការគាំទ្រក្នុងស្ថានការណ៍មានសង្គ្រាម និងប្រឆាំងនឹងអាជីវកម្មសេដ្ឋកិច្ចកាមគុណលើកុមារជាដើម ដើម្បីឲ្យពួកគេមានភាពលូតលាស់យ៉ាងងាយស្រួល ក្នុងការរស់នៅប្រកបដោយភាពប្រក្រតីខ្លាំងលើផ្នែករាងកាយ សីលធម៌ស្មារតី និងសតិបញ្ញាក្នុងលក្ខខណ្ឌនៃសេរីភាព។ ថែមពីនេះ គឺដើម្បីការពារកុមារឲ្យរួចផុតពីការរំលោភបំពានផ្សេងៗ ពិសេសឲ្យជៀសផុតពីការជួញដូរ ការកេងប្រវ័ញ្ចកំលាំងពលកម្មជាដើម។

ជាមួយគ្នានេះផងដែរ ការសុំកូនមានតាំងពីយូរលង់ណាស់មកហើយ នៅក្នុងសង្គមខ្មែរគ្រាន់តែជាការអនុវត្តការសុំកូននោះជូនកាលត្រឹមត្រូវតាមនីតិវិធីច្បាប់បានកំណត់ ហើយខ្លះគឺមិនត្រឹមត្រូវទាំងស្រុងនោះទេ។ ដោយចាប់ពីឆ្នាំ ១៩៨៩មក នីតិវិធីសុំកូនគឺត្រូវបានគោរពតាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារដែលយើងកត់សម្គាល់ឃើញថាមិនទាន់មានលក្ខណៈគ្រប់គ្រាន់ឡើយ។

សារណាមួយនេះ គឺពិតជាមានសារៈសំខាន់ណាស់ចំពោះនីតិវិធីទាក់ទងទៅនឹងការសុំកូនដែលស្របទៅតាមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ពីព្រោះនីតិវិធីនៃការដំណើរការសុំកូនអាចប្រព្រឹត្តទៅបានលុះត្រាតែរាល់អ្នកដែលជាប់ពាក់ព័ន្ធនឹងអាជ្ញាធរដែលមានសមត្ថកិច្ច តម្រូវឲ្យមានចំណេះដឹងគ្រប់គ្រាន់តាមរយៈការសិក្សាស្វែងយល់។ អាស្រ័យហេតុនេះបានជារាល់លិខិតបទដ្ឋានដែលទាក់ទងនឹងវិស័យសុំកូន ក៏ដូចជាសារណានេះផ្ទាល់គឺជា កត្តាជំរុញឲ្យអ្នកដែលចង់ស្វែងយល់

បន្ថែមនូវចំណេះដឹងទាំងអស់នេះ។ សរុបមក អត្ថបទនេះពិតជាពន្លឺ ក្នុងការបង្ហាញផ្លូវរាល់ក្រសួងស្ថាប័នដែលពាក់ព័ន្ធបានយល់ច្បាស់អំពីនីតិវិធីទាំងអស់ ជូនចំពោះបុគ្គលដែលមានបំណងសុំកូនផងដែរ។

ដូច្នេះ តើការអនុវត្តនីតិវិធីសុំកូននៅព្រះរាជាណាចក្រកម្ពុជាត្រូវប្រព្រឹត្តឡើងយ៉ាងដូចម្តេច? ដើម្បីជាការដោះស្រាយអំពីបញ្ហានេះ បទបង្ហាញបានបែងចែកជា ៣ជំពូក ៖

- **ជំពូកទី១** និយាយអំពី **ទស្សនៈទានទូទៅនៃសុំកូន** ដែលក្នុងនោះដែរមានចំនួន ២ផ្នែកទៀត ដែលទាក់ទងនឹងផ្នត់គំនិតគោលនៃការសុំកូន និង សារៈប្រយោជន៍នៃការសុំកូន។
- **ជំពូកទី២** និយាយអំពី **លក្ខខណ្ឌនៃការសុំកូន** ដែលចំណុចនេះនឹងបង្ហាញអំពីលក្ខខណ្ឌផ្សេងៗទាក់ទងទៅនឹងនីតិវិធីនៃការសុំកូន។
- **ជំពូកទី៣** ដែលជាជំពូកចុងក្រោយនឹងបកស្រាយអំពី **អានុភាព និងបញ្ហាចោទជុំវិញសុំកូន**។

# ជំពូកទី១
# ទស្សនៈទានទូទៅនៃសុំកូន

## ផ្នែកទី១ ៖ ផ្នត់គំនិតគោលនៃសុំកូន

ជាទូទៅ បុគ្គលគ្រប់រូបតែងប្រាថ្នាចង់រស់រានមានជីវិតសមស្រប ទទួលបានការយកចិត្តទុកដាក់ពីឪពុកម្ដាយ ឬ អាណាព្យាបាលរបស់ខ្លួន។ ដោយឡែក ប្រសិនបើប្រមើលមើលទៅលើទិដ្ឋភាពខ្លះៗដែលកើតមានចំពោះកុមារមួយចំនួនខ្វះភាពកក់ក្ដៅទាំងស្រុង ឬមិនមានការមើលថែអោយបានជិតដល់ ហេតុដូចនេះទើបបង្កើតអោយមានការសុំកូន **ទី១** ផ្ដល់អត្ថប្រយោជន៍ចំពោះកុមារ និង **ទី២** ចំពោះឪពុកម្ដាយ ឬ អាណាព្យាបាលដែលទន្ទឹងចង់បានកូនយកមកចិញ្ចឹម។ ឆ្លើយតបទៅនឹង គោលដៅសង្គ្រោះចំពោះមុខទៅលើស្ថានភាពកុមារក្រីក្រ និង កំព្រា ច្បាប់សុំកូនបានផ្ដល់លទ្ធភាពចំពោះកុមារ និង អាណាព្យាបាលស្របច្បាប់នៃឪពុកម្ដាយសុំ ទទួលបាននូវគ្រួសារថ្មីមួយមានភាពពេញលេញ ជាគ្រួសារតាមន័យសង្គមសាស្ត្រ (ឪពុក ម្ដាយ និង បុត្រធីតា) លើសពីនេះទៅទៀត ទប់ស្កាត់រាល់សកម្មភាពជួញដូរ និង កេងប្រវ័ញ្ចលើពលកម្មកុមារ ទាំងកម្លាំងចិត្ត និង កម្លាំងកាយ។

ដូចមានចែងក្នុងក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ បានបញ្ញត្តិអំពីសុំកូនមានចំនួន ២៧មាត្រា ចាប់ពីមាត្រា ១០០៧ ដល់មាត្រា ១០៣៣។ ក្នុងនោះមាត្រា ១០០៧ ដែលបានផ្ដល់អំណាចទាំងស្រុងដល់តុលាការក្នុងការពិចារណា និងសម្រេចលើការសុំកូន។ ច្បាប់នេះធ្វើឡើង ស្របតាមកម្មវិធីនយោបាយ យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជាដំណាក់កាលទី២ នៃនីតិកាលទី៤ របស់រដ្ឋសភាដែលមានខ្លឹមសារជាអាទិ៍ "រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការគ្រប់បែបយ៉ាងដើម្បីទប់ស្កាត់អំពើគាបសង្កត់ អំពើពេស្យាចារលើកុមារ ការជួញដូរកុមារ ការពង្រឹងលើការអនុវត្តច្បាប់ ការកែប្រែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌"។ យោងតាមគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិ (UN) បានចែងថា "សុំកូនក្នុងប្រទេស គឺសំដៅដល់ការថែទាំដែលផ្ដល់ទៅឲ្យកុមារដែលមិនស្ថិតនៅក្រោមការថែទាំរបស់ឪពុកម្ដាយបង្កើតរបស់ខ្លួន"[១]។

---

[១]សេចក្ដីពន្យល់អំពីសុំកូនក្នុងប្រទេស (ខែសីហា ឆ្នាំ២០១៦)

វត្ថុបំណងនៃសុំកូន គឺផ្តោតសំខាន់លើគោលការណ៍មនុស្សធម៌សុទ្ធសាធដោយផ្សារភ្ជាប់នូវការយកចិត្តទុកដាក់ចំពោះកុមារ ដើម្បីផ្តល់ជូននូវការការពារកុមារឲ្យរួចផុតពីការរំលោភបំពានផ្សេងៗ ផ្តល់នូវការចិញ្ចឹមថែរក្សាបីបាច់ ផ្តល់សេវាសុខភាព ការអប់រំរៀនសូត្រ។

ជាពិសេស ការគិតគូរទៅលើការគោរពសិទ្ធិជាមូលដ្ឋានរបស់កុមារ សិទ្ធិទទួលបានការការពារទទួលបានការរៀនសូត្រ ការអភិវឌ្ឍន៍ និងសិទ្ធិក្នុងការចូលរួមនានា ដើម្បីជាឧត្តមប្រយោជន៍កុមារនៅពេលអនាគត។

### ១.១. នីតិវិធីច្បាប់

យោងតាមមាត្រា ៣ វិសាលភាពនៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងបានចែងថា:

១.ក្នុងចំណោមចំណុចដែលស្ថិតនៅក្រោមសិទ្ធិអំណាចរបស់តុលាការដោយយោងតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ចំពោះចំណុចដែលកំណត់ក្នុងផ្នែកនីមួយៗនៃតារាងឧបសម្ព័ន្ធតុលាការត្រូវសម្រេចសេចក្តីតាមបញ្ញាត្តិនៃច្បាប់នេះ លើកលែងតែករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់ផ្សេងៗ។

២.ការសម្រេចសេចក្តីដែលកំណត់ក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវធ្វើឡើងដោយដីកាសម្រេច។

៣.ក្រៅពីករណីដែលមានបញ្ញត្តិពិសេសនៅក្នុងច្បាប់នេះ បញ្ញត្តិស្តីពីដីកាសម្រេចដូចមានចែងនៅក្នុងក្រមរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះដីកាសម្រេចដែលកំណត់ក្នុងកថាខណ្ឌទី២ខាងលើនេះ[២]។

គ្រប់បុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម និងបុគ្គលដែលនឹងក្លាយជាកូនចិញ្ចឹមត្រូវដាក់ពាក្យសុំទៅតុលាការ។ បន្ទាប់ពីដាក់ពាក្យសុំរួចមក តុលាការចេញដីកាសម្រេចដែលទទួលស្គាល់សុំកូននោះ។ ម៉្យាងវិញទៀត ក្រៅពីករណីមានបញ្ញត្តិពិសេសដែលបានចែងនៅក្នុងច្បាប់នេះបញ្ញត្តិ

[២]សេចក្តីពន្យល់អំពីសុំកូនក្នុងប្រទេស (ខែសីហា ឆ្នាំ២០១៦)

ស្តីពីដីកាសម្រេចដូចមានចែងនៅក្នុង **ក្រមនីតិវិធីរដ្ឋប្បវេណី** ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះដីកាសម្រេចស្តីពីសុំកូនពេញលេញ និងសុំកូនធម្មតា[៣]។

**១.១.១ ការដាក់ពាក្យសុំ**

បុគ្គលដែលនឹងក្លាយជាឪពុកម្តាយសុំ ចាំបាច់ត្រូវតែដាក់ពាក្យសុំទៅតុលាការ ចំពោះតតិយជនណាផ្សេងក្រៅពីឪពុកម្តាយចិញ្ចឹមនោះ មិនអាចដាក់ពាក្យសុំបានឡើយ។ ការដាក់ពាក្យស្នើសុំទៅតុលាការជាវិធានការចាំបាច់ ព្រោះតុលាការមិនមានអំណាចឆន្ទានុសិទ្ធិសម្រេចសុំកូនដោយគ្មានពាក្យសុំពីអាណាព្យាបាលសុំឡើយ។

នៅក្នុងលិខិតនៃពាក្យសុំឲ្យបង្កើតសុំកូនត្រូវសរសេរបញ្ជាក់នូវចំណុចខាងក្រោមនេះ ៖

(១). ឈ្មោះ និងអាសយដ្ឋានរបស់អ្នកដាក់ពាក្យសុំ

(២). ខ្លឹមសារនៃដីកាសម្រេច

(៣).អង្គហេតុដែលជាមូលហេតុនៃការទាមទារ[៤]។

**១.១.២. ការដកពាក្យសុំ**

អ្នកដាក់ពាក្យសុំអាចដកពាក្យសុំវិញបាន រហូតដល់ពេលដែលដីកាសម្រេចស្តីពីសុំកូនចូលជាស្ថាពរ ប្រសិនបើពាក្យសុំត្រូវបានដក ដូច្នេះនីតិវិធីតុលាការសម្រាប់សុំកូនក៏ត្រូវបញ្ចប់ដែរ[៥]។ ទោះបីជាបុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម និងបុគ្គលដែលនឹងក្លាយជាកូនសុំត្រូវដាក់ពាក្យសុំដោយតុលាការក៏ដោយក៏ភាគីតែម្ខាងអាចដកពាក្យសុំបាន។ យោងតាមកាលៈទេសៈ តុលាការត្រូវចេញដីកាសម្រេចលើកចោលតាមពាក្យសុំរបស់ភាគីពាក់ព័ន្ធ។

**១.២. ការវិវត្តន៍នៃសង្គម**

គិតចាប់ពីឆ្នាំ ១៩៨៩ ដល់ ២០០៧ មានច្បាប់ពីរសំខាន់ពាក់ព័ន្ធនឹងបញ្ហាសុំកូនៈ

ក. ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ ចាប់ពីមាត្រា ១០៨ ដល់មាត្រា ១២២ ។

ខ. ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។

[៣]មាត្រា៣ កថាខណ្ឌទី៣ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង
[៤]មាត្រា២៦ នៃច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង
[៥]មាត្រា២១៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី

គ. ភាពខុសគ្នារវាងច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ និង ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧៖

គ.១. ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ សុំកូនពុំត្រូវកម្រិតចំពោះបរិមាណនៃកូនសុំ ថែមទាំងមិនដាក់កំហិតចំពោះការស្នើសុំទៅតុលាការទៀត។

គ.២. ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ សុំកូនត្រូវបានកម្រិតបរិមាណ ជាគោលការណ៍មិនឲ្យលើសពីពីរនាក់ ហើយត្រូវតែដាក់ពាក្យស្នើសុំទៅតុលាការ។

បច្ចុប្បន្ន រាជរដ្ឋាភិបាលបានបង្កើតជាយន្តការក្នុងការទប់ស្កាត់ចំពោះការសុំ ត្រូវមានការធានាថា កុមារដែលជាកូនសុំត្រូវមានសិទ្ធិទទួលបាននូវការការពារ ដែលក្នុងនោះមាន សិទ្ធិការពារទប់ស្កាត់ និងប្រឆាំងចំពោះការជិះជាន់ និង ការរំលោភបំពានសិទ្ធិរបស់កុមារ។ លើសពីនេះ កុមារត្រូវរួចផុតអំពីការកេងប្រវ័ញ្ចនានា ដូចជាការរួចផុតពីការធ្វើពលកម្ម និងការរួចផុតពីអំពើកេងប្រវ័ញ្ចលើសិទ្ធិសុំកូន ដែលមានន័យថា កូនសុំក៏មានសិទ្ធិគ្រប់គ្រាន់ទៅតាមផ្លូវច្បាប់ដូចកុមារដទៃទៀតដែរ។ ជាពិសេស រដ្ឋក៏ត្រូវទប់ស្កាត់នូវការជិះជាន់លើផ្លូវភេទ ការពង្រាត់ ការលក់ដូរ និងការជួញដូរកុមារជាដើម។

**១.៣. ស្ថានភាពគ្រួសារ**

បុគ្គលដែលអាចធ្វើការសុំកូនបានត្រូវតែ មានលក្ខណៈសម្បត្តិសមស្របទៅតាមតម្រូវការនៃនីតិវិធីច្បាប់ដែលបានចែងអំពី ទីលំនៅឋានអចិន្ត្រៃយ៍ ជីវភាព សីលធម៌ និងគុណធម៌ក្នុងការយកកូនមកចិញ្ចឹមដែលស្ថិតនៅក្រោមការថែទាំដោយយកចិត្តទុកដាក់ ទោះបីជាកូនសុំមកនោះ មិនមែនជាកូនបង្កើតរបស់ខ្លួនក៏ដោយ។ ជាក់ស្តែងពួកគេត្រូវមានការផ្គត់ផ្គង់តាមលទ្ធភាពដែលអាចធ្វើទៅបានដូចជា ការផ្តល់ទៅលើការសិក្សាអប់រំ ការហូបចុកគ្រប់គ្រាន់ ការស្នាក់នៅល្អ ការលើកទឹកចិត្ត ការចិញ្ចឹមបីបាច់ថែរក្សា និងការការពារសិទ្ធិជាមូលដ្ឋានរបស់កុមារនោះជាចាំបាច់។ ម៉្យាងទៀត បុគ្គលដែលធ្វើការសុំកូននោះ មិនត្រូវសុំយកមកធ្វើជាអំពើអនាចារ[៦] ដើម្បីជាអត្ថប្រយោជន៍ផ្ទាល់ខ្លួននោះទេ។

[៦] វចនានុក្រមខ្មែរ ភាគទី១ ដោយគ្រឹះស្ថានបោះពុម្ពក្រសួងអប់រំ ឆ្នាំ២០០១

## ផ្នែកទី២ ៖ សារៈប្រយោជន៍នៃសុំកូន

ស្មុំកូនបានផ្តល់ផលប្រយោជន៍ជាច្រើន ចំពោះបុគ្គលដែលចង់បានកូនមកធ្វើការចិញ្ចឹមដោយផ្ទាល់ខ្លួន និងកូនដែលមិនមានការថែទាំគ្រប់គ្រាន់ ឲ្យក្លាយទៅជាបុគ្គលដែលមានគ្រួសារមួយពេញលេញ។

ស្មុំកូនមានគោលបំណងចម្បងក្នុងការធានាបាននូវឧត្តមប្រយោជន៍ និង ការការពារសិទ្ធិជាមូលដ្ឋានរបស់ក្មេងដូចជា កុមារដែលមានឪពុកម្តាយក្រីក្រ ដែលត្រូវការកិច្ចការពារពិសេសដើម្បីធ្វើឲ្យពួកគេបានរស់នៅក្នុងមជ្ឈដ្ឋានសមស្រប ឬការអភិវឌ្ឍន៍ ក្នុងបរិយាកាសគ្រួសារថ្មីមួយប្រកបដោយ សុភមង្គល សេចក្តីស្រលាញ់ និងការយោគយល់។ លើសពីនេះទៅទៀត ដោយមានការយកចិត្តទុកដាក់យ៉ាងខ្លាំងពីសំណាក់ស្ថាប័នជាតិដែលជាកំលាំងចលករដ៏សំខាន់ ក្នុងការជំរុញឲ្យកុមារកំព្រាទាំងឡាយ ទទួលបានការរស់នៅក្នុងមជ្ឈដ្ឋានគ្រួសារថ្មីមួយដែលពោរពេញទៅដោយករុណាធម៌ ការយកចិត្តទុកដាក់ ការទទួលខុសត្រូវនានា ដើម្បីឲ្យកុមារទទួលបានអនាគតភ្លឺស្វាងដូចកុមារដទៃ។

### ២.១. ចំពោះសង្គម

ការធានាឧត្តមប្រយោជន៍ និង កិច្ចការពារសិទ្ធិកុមារដែលជាកាតព្វកិច្ចរបស់យើងទាំងអស់គ្នាដែលត្រូវគិតគូរឲ្យកុមារមានការរីកចំរើនធំធាត់ និងអភិវឌ្ឍន៍នៅក្នុងគ្រួសារមួយដ៏ល្អប្រកបដោយភាពកក់ក្តៅ និងគ្មានការបំពានសិទ្ធិ។ ផ្ទុយមកវិញ បើការទុកដាក់កុមារនៅក្នុងគ្រួសារមួយ ដែលមិនមានលក្ខណៈសមស្រប វានឹងធ្វើឲ្យប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍របស់កុមារជាមិនខានដែលជាកត្តានាំឲ្យជះឥទ្ធិពលដល់សង្គមនាពេលអនាគត ព្រោះថាកុមារគឺជាអនាគតសសរទ្រូងសំរាប់ស្នងប្រទេសជាតិ។ ម៉្យាងវិញទៀត បានធ្វើឲ្យអត្រានៃកុមារកំព្រាបានថយចុះ ព្រមទាំងធ្វើឲ្យសង្គមទាំងមូលទទួលបានការរីកចម្រើនដូចជា កត្តាសេដ្ឋកិច្ច កត្តាអប់រំ កត្តាផ្សេងៗទៀតដែលបានផ្តល់ផលប្រយោជន៍ជាច្រើនដល់ប្រទេសជាតិ។ ដូចនេះ យើងទាំងអស់គ្នា គួរតែយកចិត្តទុកដាក់ទៅលើកុមារឲ្យបានច្រើន ដើម្បីឲ្យកុមារទាំងអស់ទទួលបានគ្រួសារមួយដែលសមស្របក្នុងការរស់នៅ ដែលជាកត្តាដ៏សំខាន់ដែលជំរុញឲ្យប្រទេសជាតិមានការអភិវឌ្ឍន៍រីកចម្រើនទៅថ្ងៃអនាគត។

**២.២. ចំពោះបុគ្គល**

ស្មុំកូនបានផ្តល់ផលប្រយោជន៍ជាច្រើន ដែលអាចធ្វើឲ្យកុមារមានទំនាក់ទំនងរវាងឪពុកម្តាយនឹងកូនជាអចិន្ត្រៃយ៍ និង រវាងកូនចិញ្ចឹមនឹងឪពុកម្តាយចិញ្ចឹមដោយបង្កើតជាគ្រួសារមួយពេញលេញ ។

**២.២.១. ចំពោះឪពុកម្តាយចិញ្ចឹម**

ឪពុកម្តាយចិញ្ចឹម ជាកត្តាដែលទទួលបានការគ្រប់គ្រងថែរក្សាលើកូនសុំ ដោយពេញលេញដូចជាកូនបង្កើតរបស់ខ្លួនក្នុងការការពារសិទ្ធិសេរីភាពរបស់កូនស្មុំ និង ទទួលបានសិទ្ធិក្នុងការធានាដល់អត្ថប្រយោជន៍ និងករណីយកិច្ចនានាដែលអាចធ្វើទៅបានតាមលទ្ធភាព។ ជាពិសេស ឪពុកម្តាយចិញ្ចឹមមានអំណាចមេបាលើកូនស្មុំនោះ និងមានកាតព្វកិច្ចចាត់ចែងរាល់អ្វីដែលជាតម្រូវការរបស់ខ្លួន។ ប៉ុន្តែការប្រើប្រាស់នូវតម្រូវការនោះ មិនត្រូវធ្វើអោយប៉ះពាល់ដល់សិទ្ធិរបស់កូនស្មុំនោះដើម្បីធ្វើជាការបម្រើផលប្រយោជន៍ផ្ទាល់ខ្លួននោះឡើយ។

**២.២.២. ចំពោះកូនចិញ្ចឹម**

កូនចិញ្ចឹម ជាកត្តាដែលបង្កើតឲ្យមានអនុភាពរវាងកូនសុំ និងឪពុកម្តាយចិញ្ចឹម គឺកូនស្មុំត្រូវតែកាត់ផ្តាច់ចំណងញាតិភាពជាមួយឪពុកម្តាយបង្កើត ហើយកូនស្មុំត្រូវតែទទួលបាននូវសិទ្ធិ និងករណីយកិច្ចដូចកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹមដែរ រីឯអំណាចមេបាត្រូវប្រគល់ទៅឲ្យឪពុកម្តាយចិញ្ចឹមជាអ្នកទទួលបន្ទុកគ្រប់គ្រងថែរក្សា។ ជាពិសេស ទទួលបានគ្រួសារថ្មីមួយដែលពេញលេញប្រកបទៅដោយភាពសុភមង្គល។

# ជំពូកទី២
# លក្ខខណ្ឌគ្រឹះ និងលក្ខខណ្ឌទម្រង់នៃសុំកូន

## ផ្នែកទី១ ៖ ចំពោះសុំកូនពេញលេញ

**សុំកូនពេញលេញ** គឺសំដៅដល់សេចក្ដីសម្រេចរបស់តុលាការតាមនីតិវិធីច្បាប់ ក្នុងការទុកដាក់ចំពោះកុមារ និងបង្កើតឲ្យមានទំនាក់ទំនងឪពុកម្ដាយកូនជាអចិន្ត្រៃយ៍រវាងកូនចិញ្ចឹម និងឪពុកម្ដាយចិញ្ចឹម និង បញ្ចប់សិទ្ធិ និង កាតព្វកិច្ចរវាងកុមារ និង ឪពុកម្ដាយបង្កើត ឬអាណាព្យាបាលរបស់កុមារ។

បើសំរាយឲ្យកាន់តែងាយស្រួលក្នុងការយល់ **សុំកូនពេញលេញ** គឺជាការសុំអនីតិជន ដែលមានអាយុក្រោម ៨ (ប្រាំបី)ឆ្នាំ យកមកធ្វើជាកូនសុំដោយបញ្ចប់ញាតិជាមួយនឹងញាតិលោហិតនៃឪពុកម្ដាយបង្កើត ហើយការសុំនេះត្រូវសម្រេចដោយតុលាការ។

របបសុំកូនពេញលេញ កូនសុំនឹងត្រូវកាត់ផ្ដាច់នូវរាល់ទំនាក់ទំនងគតិយុត្តទាំងអស់ជាមួយនឹងឪពុកម្ដាយបង្កើតរបស់ខ្លួន និងផ្សារភ្ជាប់ទំនាក់ទំនងយ៉ាងពេញលេញជាមួយនឹងឪពុកម្ដាយចិញ្ចឹមដូចគ្នានឹងកូនបង្កើតរបស់ឪពុកម្ដាយចិញ្ចឹម។ ម៉្យាងទៀត ការបង្កើតសុំកូនពេញលេញអាចធ្វើឡើង ដោយបញ្ចប់ញាតិភាពជាមួយនឹងញាតិលោហិតរបស់ឪពុកម្ដាយបង្កើត តាមពាក្យសុំរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹមបាន។ ចំពោះកូនសុំនេះ បានបង្កើតអានុភាពឲ្យមានចំណងញាតិលោហិត និង សិទ្ធិកាតព្វកិច្ចក្នុងទំនាក់ទំនងញាតិ ហើយសុំកូននេះដែរ ក៏ត្រូវប្រឈមនឹងការកាត់កាល់ដោយមានមូលហេតុផ្សេងៗផងដែរ។

សុំកូនពេញលេញ សំដៅដល់កូនដែលមានអានុភាពបង្កើតនូវទំនាក់ទំនងអចិន្ត្រៃយ៍ជាឪពុកម្ដាយនឹងកូន រវាងឪពុកម្ដាយចិញ្ចឹម ឬ ឪពុកចិញ្ចឹម ឬ ម្ដាយចិញ្ចឹមនឹងកូនសុំ និងបញ្ចប់សិទ្ធិ និងកាតព្វកិច្ចរវាងកូននឹងឪពុកម្ដាយបង្កើត ឬអាណាព្យាបាលសំរាប់អនីតិជនរបស់ខ្លួន។ អាចនិយាយបានថា ដោយបង្កើតសុំកូនពេញលេញ កូនសុំត្រូវទទួលបាននូវឋានៈដូចគ្នានឹងកូនបង្កើតរបស់ឪពុកម្ដាយចិញ្ចឹម និង ត្រូវទទួលបានសិទ្ធិ និងករណីយកិច្ចដូចគ្នានឹងកូនបង្កើតនៅក្នុងទំនាក់ទំនងជាមួយឪពុកម្ដាយចិញ្ចឹម។ ញាតិភាពរវាងកូនសុំនឹងឪពុកម្ដាយបង្កើតត្រូវបានបញ្ចប់ដោយកូន

សុំពេញលេញលើកលែងតែចំពោះសហព័ទ្ធម្ខាងក្លាយជាឪពុកម្ដាយ ឬ ម្ដាយចិញ្ចឹមនៃកូនចិញ្ចឹមនៃកូនបង្កើតរបស់សហព័ទ្ធម្ខាងទៀត[៩]។

យោងតាមការបកស្រាយខាងលើ យើងអាចនិយាយបានថា កាលណាមានការបង្កើតសុំកូនពេញលេញនាំឲ្យមានស្ថានភាពពីរកើតឡើង៖ *ទី១* គឺបង្កើតនូវទំនាក់ទំនង ឬ ញាតិភាពរវាងកូនសុំជាមួយជាមួយឪពុកម្ដាយចិញ្ចឹមដូចជាកូនបង្កើត ពោលគឺមានសិទ្ធិ និងកាតព្វកិច្ចដូចនឹងឪពុកម្ដាយបង្កើត។ *ទី២* គឺបញ្ចប់ទំនាក់ទំនងជាមួយឪពុកម្ដាយបង្កើត ក៏ដូចជាញាតិលោហិតរបស់ឪពុកម្ដាយបង្កើត ពោលគឺបញ្ចប់សិទ្ធិ និង កាតព្វកិច្ចជាកូននឹងឪពុកម្ដាយបង្កើត។

លក្ខខណ្ឌនេះ មិនមែនមានចំពោះតែភាគីម្ខាងៗនោះទេ គឺមានទាំងចំពោះឪពុកម្ដាយចិញ្ចឹម ឬ ឪពុកចិញ្ចឹម ឬ ម្ដាយចិញ្ចឹម ក៏ដូចជាចំពោះកូនចិញ្ចឹមដែរ ហេតុនេះលក្ខខណ្ឌទាំងនោះ នឹងលំអិតចំពោះភាគីទាំងសងខាង។

សរុបមក សុំកូនពេញលេញ គឺជាប្រព័ន្ធមានគោលបំណងផ្ដល់នូវគ្រួសារដែលមានឪពុកម្ដាយ និងមានលំនឹងគ្រប់គ្រាន់ដល់កុមារដែលមិនស្ថិតនៅក្រោមការថែទាំរបស់ឪពុកម្ដាយបង្កើតរបស់ខ្លួន។

### ១.១. កត្តាបុគ្គល

#### ១.១.១. លក្ខខណ្ឌចំពោះឪពុកម្ដាយចិញ្ចឹម

យោងតាមក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានបង្ហាញពីលក្ខខណ្ឌនៃការសុំកូនពេញលេញអាចប្រព្រឹត្តទៅបាន លុះត្រាតែ ឪពុកម្ដាយចិញ្ចឹមទាំងពីរនោះមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទៅតាមលក្ខខណ្ឌដែលបានកំណត់ដោយច្បាប់ ហើយត្រូវបានតុលាការប្រកាសអនុញ្ញាតឲ្យមានការសុំកូនពេញលេញនេះ។ តុលាការត្រូវអនុវត្តទៅតាមស្ថានភាពជាក់ស្ដែង និងតាមពាក្យសុំបញ្ចប់នូវរាល់ទំនាក់ទំនងញាតិ រវាងឪពុកម្ដាយជាមួយនឹងបុគ្គល ដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹម។

[៩]មាត្រា៩ នៃច្បាប់ស្ដីពីសុំកូនអន្តរប្រទេស មាត្រា១០០៧ និងមាត្រា១០១៤-១០១៥ នៃក្រមរដ្ឋប្បវេណី

**១.១.១.១. អាយុ**

ឪពុកម្ដាយចិញ្ចឹម ឬ ឪពុកចិញ្ចឹម ឬ ម្ដាយចិញ្ចឹម ត្រូវមានអាយុចាប់ពី ២៥ (ម្ភៃប្រាំ) ឆ្នាំ ឡើងទៅ ហើយត្រូវមានអាយុច្រើនជាងកូនចិញ្ចឹមយ៉ាងតិច ២០ (ម្ភៃ) ឆ្នាំ[៨]។ លក្ខខណ្ឌមួយនេះ តម្រូវឲ្យមានភាពសមស្របរវាងលក្ខខណ្ឌនៃអ្នកដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹម និងកូនសុំ ដែលអាចឲ្យពួកគេមានគម្លាតអាយុដ៏សមស្របដូចជាឪពុកម្ដាយ និង កូនបង្កើតដែរ។ ហេតុដូចនេះ ចំពោះឪពុកម្ដាយចិញ្ចឹម ឬឪពុកចិញ្ចឹម ឬម្ដាយចិញ្ចឹមដែលមានអាយុ ២៥ឆ្នាំ អាចសុំកូនដែលមានអាយុតិចជាង ៥ (ប្រាំ) ឆ្នាំ។ ហើយមានអាយុតិចជាងឪពុកម្ដាយចិញ្ចឹម ឬម្ដាយចិញ្ចឹមយ៉ាងតិចណាស់ ២០ (ម្ភៃ)ឆ្នាំ។ **ឧទាហរណ៍** ៖ លោក A និង នាង B ជាប្ដីប្រពន្ធ។ លោក A មានអាយុ ៣០ឆ្នាំ រីឯនាង B មានអាយុ ២៦ឆ្នាំ។ ពួកគេចង់សុំកូនឈ្មោះ C យកមកចិញ្ចឹមដោយសុំកូនពេញលេញដោយ C មានអាយុ ៦ឆ្នាំ។ ដូច្នេះ ក្នុងករណីនេះ ពួកគេអាចធ្វើការសុំកូនបាន ពីព្រោះគម្លាតរវាងអាយុរបស់នាង B និងអាយុរបស់ C គឺសមស្របទៅតាមច្បាប់កំណត់ ។

**១.១.១.២. ស្ថានភាពគ្រួសារ**

បុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹម ឬ ឪពុកចិញ្ចឹម ឬ ម្ដាយចិញ្ចឹម ត្រូវតែជាបុគ្គលដែលមានសហព័ទ្ធ[៩]។ ក្នុងនាមជាសហព័ទ្ធនេះ គឺត្រូវមានការសហការគ្នា និងឯកភាពរវាងប្ដីប្រពន្ធ បើមិនដូច្នេះទេ ប្ដី ឬ ប្រពន្ធតែម្ខាងមិនអាចក្លាយជាឪពុក ឬម្ដាយចិញ្ចឹមបានឡើយ បើសហព័ទ្ធម្ខាងទៀតមិនមែនជាឪពុក ឬ ម្ដាយចិញ្ចឹមនៃកូនសុំនោះ តែលើកលែងចំពោះសហព័ទ្ធក្លាយជា ឪពុក ឬ ម្ដាយចិញ្ចឹមនៃកូនបង្កើតរបស់សហព័ទ្ធម្ខាងទៀត[១០]។

**១.១.១.៣. ជីវភាព**

តុលាការត្រូវពិចារណាលើស្ថានភាព ចំពោះបុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹមបានធ្វើក្នុងការគ្រប់គ្រងថែរក្សាកុមារ ដែលនឹងក្លាយជាកូនសុំជាគោលការណ៍យ៉ាងតិច ៦ (ប្រាំមួយ) ខែ។ បានសេចក្ដីថា ក្នុងករណីចាំបាច់មុននឹងអនុញ្ញាតឲ្យមានការសម្រេចសុំកូនពេញលេញ តុលាការត្រូវកំណត់ឲ្យឪពុកម្ដាយចិញ្ចឹមធ្វើការចិញ្ចឹមកូនសុំនោះនៅក្នុងបន្ទុករបស់ខ្លួនរយៈពេល ៦(ប្រាំមួយ)

[៨]មាត្រា១០០៩ នៃក្រមរដ្ឋប្បវេណី២០០៧
[៩]កថាខណ្ឌទី១ ក្នុងមាត្រា១០០៨ នៃក្រមរដ្ឋប្បវេណី២០០៧
[១០]កថាខណ្ឌទី២ ក្នុងមាត្រា១០០៨ នៃក្រមរដ្ឋប្បវេណី២០០៧

ខែសិន ដើម្បីពិនិត្យ និងវាយតម្លៃពិចារណាថា តើឪពុកម្តាយចិញ្ចឹមនោះពិតជាមានលក្ខណសម្បត្តិ សមត្ថភាព និង លទ្ធភាពទំនុកបំរុងក្នុងការចិញ្ចឹមបីបាច់កូនសុំនោះបានល្អដែរឬទេ?

**១.១.២. លក្ខខណ្ឌចំពោះកូនសុំពេញលេញ**

ចំនួនកូនសុំ បានចែងក្នុងមាត្រា ១១១ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារបានកំណត់ថា គេអាចសុំកូនបានតែ ២ (ពីរ) នាក់ប៉ុណ្ណោះ។ បើកូនសុំនោះមានមួយណាស្លាប់ គេអាចសុំកូនម្នាក់ទៀត។ ប៉ុន្តែក្នុងក្រមរដ្ឋប្បវេណី មិនមានមាត្រាណាមួយកំណត់អំពីចំនួននៃកូនសុំឡើយ ហេតុនេះ នៅពេលក្រមរដ្ឋប្បវេណី ២០០៧ បានចូលជាធរមាន តើចំនួនកូនសុំត្រូវកំណត់យ៉ាងដូចម្តេច?

**១.១.២.១. អាយុ**

ជាគោលការណ៍កូនសុំត្រូវតែមានអាយុយ៉ាងតិច ៨ (ប្រាំបី)ឆ្នាំ[១១]។ ហេតុដូច្នេះ ចំពោះឪពុក-ម្តាយចិញ្ចឹម ឬ ឪពុកចិញ្ចឹម ឬ ម្តាយចិញ្ចឹម ដែលមានអាយុតិចជាងម្តាយឪពុកចិញ្ចឹម ឬ ឪពុកចិញ្ចឹម ឬ ម្តាយចិញ្ចឹមយ៉ាងតិច ២០ (ម្ភៃ) ឆ្នាំ។ ហើយសុំកូនពេញលេញបង្កើតឡើងដើម្បីកសាងទំនាក់ទំនង ដោយយកឪពុកម្តាយចិញ្ចឹមមកធ្វើជាមេបាតែមួយគូ ដូចគ្នាជាមួយនឹងទំនាក់ទំនងជាមួយកូនបង្កើតដែរ។ **ឧទាហរណ៍:** លោក **ដារីត** និងនាង **បុស្បា** ជាប្តីប្រពន្ធនឹងគ្នា ហើយចង់សុំកុមារម្នាក់ឈ្មោះ **លីកា** យកមកចិញ្ចឹមតាមរយៈសុំកូនពេញលេញ។ នៅពេលពួកគេ បានដាក់ពាក្យសុំនៃសុំកូនពេញលេញទៅតុលាការ **លីកា** មានអាយុ៧ឆ្នាំហើយ ដូចនេះនៅពេលដាក់ពាក្យសុំ លោក**ដារីត** និងនាង **បុស្បា** ត្រូវភ្ជាប់ជាមួយនូវសំបុត្រកំណើតរបស់ **លីកា**។ ក្រោយពីការដាក់ពាក្យសុំខាងលើនេះ បានប្រើអស់រយៈពេលជាងមួយឆ្នាំ សម្រាប់នីតិវិធីតុលាការនៃសុំកូនពេញលេញ ដែលរួមមានអំឡុងពេលសាកល្បងចិញ្ចឹម (មាត្រា ១០១៣ នៃក្រមរដ្ឋប្បវេណី) ។

ក្នុងករណីនេះ នៅពេលតុលាការវិនិច្ឆ័យសម្រេចអំពីការដាក់ពាក្យសុំនោះ **លីកា** មានអាយុ ៨ ឆ្នាំហើយ។ ដូច្នេះ តុលាការនៅតែអាចចេញដីកាសម្រេចដែលទទួលស្គាល់សុំកូនពេញលេញបាន។ ពីព្រោះថា នៅពេលបានដាក់ពាក្យសុំនៃសុំកូនពេញលេញទៅតុលាការនោះ **លីកា** បានបំពេញនូវលក្ខខណ្ឌនៃអាយុរបស់កូនដូចមានចែងក្នុងមាត្រា ១០១០ នៃក្រមរដ្ឋប្បវេណី។

[១១]មាត្រា១០១០ នៃក្រមរដ្ឋប្បវេណី២០០៧

**១.១.២.២. ស្ថានភាពរបស់កូន**

ស្មុំកូនពេញលេញត្រូវបានបង្កើតឡើងនៅក្នុងករណីដែលមានការពិបាកខ្លាំង ឬមិនសមរម្យក្នុងការគ្រប់គ្រងកុមារដែលនឹងក្លាយជាកូនសុំដោយឪពុកម្តាយបង្កើត ឬស្ថានភាពពិសេសផ្សេងទៀត ដែលមានភាពចាំបាច់ពិសេសដើម្បីផលប្រយោជន៍របស់កូននោះ និងស្ថានភាពដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមបានធ្វើក្នុងការគ្រប់គ្រងកុមារយ៉ាងតិច ៦ ខែ។

**១.១.៣. លក្ខខណ្ឌផ្សេងៗទៀត**

កត្តាដែលបង្កើតឲ្យមានអានុភាពរវាងកូនសុំ និង ឪពុកម្តាយចិញ្ចឹមក្នុងផ្តោតលើការធានាពីអត្ថប្រយោជន៍របស់កូន គឺកូនសុំត្រូវតែផ្តាច់ញាតិភាពជាមួយឪពុកម្តាយបង្កើត ហើយកូនសុំត្រូវទទួលបានសិទ្ធិ និង ករណីយកិច្ចដូចកូនបង្កើតដែរ។ ដើម្បីបង្កើតឲ្យមានស្មុំកូនពេញលេញបានលុះត្រាតែ មានការយល់ព្រមពីឪពុកម្តាយបង្កើត ឬ អាណាព្យាបាល ចំពោះអនីតិជនរបស់កុមារដែលត្រូវជាកូនសុំនោះ។ មានន័យថា មានតែឪពុកម្តាយបង្កើត ឬ អាណាព្យាបាលទេ ដែលជាបុគ្គលស្របច្បាប់ក្នុងការបង្ហាញឆន្ទៈយល់ព្រមលើរឿងនេះ។ ផ្ទុយមកវិញ ប្រសិនបើឪពុកម្តាយបង្កើត ឬ អាណាព្យាបាលស្របច្បាប់មិនអាចបង្ហាញឆន្ទៈ ឬ ក៏មិនមានការធ្វើបាបពីឪពុកម្តាយធ្ងន់ធ្ងរ ការបោះបង់កូនដោយគំនិតទុច្ចរិត ឬ ហេតុផ្សេងៗ ដែលបំពានដល់ផលប្រយោជន៍នៃកូនសុំនោះយ៉ាងធ្ងន់ធ្ងរ បញ្ញត្តិខាងលើមិនអាចអនុវត្តបានឡើយ។ ប៉ុន្តែ ប្រសិនបើមានស្ថានភាពពិបាកក្នុងការទទួលយកការយល់ព្រមពីឪពុកម្តាយបង្កើត ឬ មានការជំទាស់ពី ឪពុកម្តាយបង្កើតបំពានយ៉ាងធ្ងន់ធ្ងរដល់ផលប្រយោជន៍របស់កុមារដែលនឹងក្លាយជាកូនសុំនោះ ការយល់ព្រមពីឪពុកម្តាយបង្កើតមិនចាំបាច់ឡើយ។

ស្មុំកូនពេញលេញ ត្រូវបានបង្កើតនៅក្នុងករណីណាដែលកុមារមានការលំបាកខ្លាំង ឬ មិនសមរម្យក្នុងការគ្រប់គ្រងថែរក្សាកុមារដែលនឹងក្លាយជាកូនសុំ ដោយម្តាយឪពុកបង្កើត ឬ ស្ថានភាពពិសេសផ្សេងៗទៀត បើយល់ឃើញថាមានភាពចាំបាច់ពិសេស ដើម្បីបំរើផលប្រយោជន៍កូននោះ។

**១.២. កត្តាចិត្តសាស្ត្រ និង ហិរញ្ញវត្ថុ**

**១.២.១. កត្តាចិត្តសាស្ត្រ**

ការបង្កើតស្មុំកូនពេញលេញ មានស្ថានភាពសមរម្យសម្រាប់ផលប្រយោជន៍របស់កូននោះ។ តុលាការត្រូវជឿជាក់ថា ការស្មុំកូនពេញលេញនោះនឹងធានាដល់អត្ថប្រយោជន៍របស់កុមារដោយ

សង្កត់ធ្ងន់ជាពិសេសថា តាមរយៈស្មុំកូននេះនឹងផ្តល់ឲ្យកុមារនូវគ្រួសារដែលមានស្ថិរភាព និងភាពសុខដុមរមនា ពីព្រោះថា រាល់ការស្មុំកូនពេញលេញត្រូវឆ្លើយតបដោយជាក់លាក់ទៅនឹងសុខុមាលភាពកុមារ និងឧត្តមប្រយោជន៍របស់កុមារ។

ដូច្នេះ ដើម្បីធានាឧត្តមប្រយោជន៍របស់កុមារខាងលើនេះ តុលាការត្រូវគិតពិចារណាព័ត៌មានផ្សេងៗដូចតទៅ (**ប្រការ ២៨ នៃប្រកាសស្តីពីនីតិវិធីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ**):

- ប្រវត្តិផ្ទាល់ខ្លួនរបស់ឪពុកម្តាយចិញ្ចឹម
- ស្ថេរភាពផ្លូវចិត្ត និង ទំនាក់ទំនងល្អរបស់ឪពុកម្តាយចិញ្ចឹម
- ឪពុកម្តាយចិញ្ចឹមមានលំនៅដ្ឋានសមរម្យ ហើយតំបន់រស់នៅមានសុវត្ថិភាព កុមារអាចទទួលបានការអប់រំគ្រប់គ្រាន់ និង ការថែទាំសុខភាពកុមារបានជិតដល់
- ឪពុកម្តាយចិញ្ចឹមមានលទ្ធភាពក្នុងការផ្តល់ការគាំទ្រផ្នែកសម្ភារៈ និង ផ្នែកផ្លូវចិត្តដល់កុមារ
- ឪពុកម្តាយចិញ្ចឹមមានឆន្ទៈពិតប្រាកដក្នុងការចិញ្ចឹមកូនសុំនោះ ឲ្យដូចគ្នាទៅនឹងកូនបង្កើតរបស់ខ្លួន
- អារម្មណ៍របស់កុមារផ្សេងទៀត (បើមាន) ដែលរស់នៅក្នុងគ្រួសារនោះ។

### ១.២.២. កត្តាហិរញ្ញវត្ថុ

ដើម្បីឲ្យការស្មុំកូនប្រកបទៅដោយភាពងាយស្រួល និងមានភាពល្អប្រសើរ នោះតុលាការត្រូវស្វែងយល់ពីកត្តាហិរញ្ញវត្ថុ ពីចំណូលជាមធ្យមរបស់ឪពុកម្តាយចិញ្ចឹមនោះ ពីស្ថានភាពប្រាក់បៀវត្សប្រចាំខែ និងការអប់រំរបស់គាត់។ ដោយឡែក ទាក់ទងទៅនឹងចំណុចនេះផងដែរ គឺជាចំណុចដែលចាំបាច់បំផុតក្នុងការយកកូនទៅចិញ្ចឹម ដើម្បីធ្វើឲ្យកូនសុំនោះ មានគ្រួសារថ្មីមួយដែលមានជីវភាពល្អប្រសើរ មានការយកចិត្តទុកដាក់ ការអប់រំដែលល្អប្រសើរ និងមានគ្រួសារដ៏កក់ក្តៅមួយដូចកុមារដទៃទៀត។

## ផ្នែកទី២ ៖ ចំពោះសុំកូនធម្មតា

**សុំកូនធម្មតា** អាចហៅម៉្យាងទៀតបានថា **សុំកូនសាមញ្ញ** គឺជាទម្រង់មួយដែលបានសម្រួលពីសុំកូនពេញលេញ។ របបដែលដាក់កូនសុំទៅក្នុងការគ្រប់គ្រងទាំងស្រុងរបស់គ្រួសារ ឪពុកម្តាយចិញ្ចឹមហើយមិនមានការកាត់ផ្តាច់នូវចំណងទំនាក់ទំនងរវាងកូនសុំ និង ឪពុកម្តាយបង្កើត។ ប្រព័ន្ធសុំកូនធម្មតានេះ ត្រូវបានបង្កើតឡើងដោយតម្រូវឲ្យមានការពាក់ព័ន្ធពីតុលាការ ដើម្បីបង្កើតអានុភាព ញាតិលោហិតតាមផ្លូវច្បាប់ដូចជាសន្តតិកម្ម និងអាហារកិច្ចជាដើម។

**សុំកូនធម្មតា** សំដៅដល់ការសុំកូនដែលកូននោះអាចជាអនីតិជន ឬ នីតិជនដោយមិនកាត់ផ្តាច់ញាតិភាពពីឪពុកម្តាយបង្កើត ហើយការសុំនេះត្រូវសម្រេចដោយតុលាការ។

**សុំកូនធម្មតា** មិនមានលក្ខណៈតឹងរឹងដូចសុំកូនពេញលេញនោះទេ។ ញាតិភាពរវាងកូនសុំ និងឪពុកម្តាយបង្កើតត្រូវបានបន្តអត្ថិភាពរហូត ហើយកូនសុំ និងឪពុកម្តាយបង្កើតមានសិទ្ធិធ្វើសន្តតិកម្មឲ្យគ្នាទៅវិញទៅមកបាន។ កូនសុំ និង ឪពុកម្តាយបង្កើតក៏មានសិទ្ធិទាមទារ និង មានករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ចផងដែរ។ លើសពីនេះ កូនសុំត្រូវទទួលបាននូវឋានៈដូចគ្នាទៅនឹងកូនបង្កើតដែរ នៅក្នុងទំនាក់ទំនងជាមួយនឹងឪពុកម្តាយចិញ្ចឹម។

### ២.១. ចំពោះឪពុកម្តាយចិញ្ចឹម

#### ២.១.១. អាយុ

បុគ្គលដែលមានអាយុចាប់ពី ២៥(ម្ភៃប្រាំ) ឆ្នាំឡើងទៅ[១២] ទើបអាចបង្កើតសុំកូនធម្មតាបាន ប៉ុន្តែសុំកូនធម្មតាមិនអាចបង្កើតបានឡើយក្នុងករណី បុគ្គលដែលនឹងក្លាយជាកូនចិញ្ចឹម មានអាយុច្រើនជាងបុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម។ ម៉្យាងវិញទៀត ការបង្កើតសុំកូនធម្មតាមិនហាមឃាត់ចំពោះបុគ្គលដែលជាញាតិនឹងគ្នាទេ ប៉ុន្តែសុំកូនមិនអាចបង្កើតបានឡើយ ក្នុងករណីបុគ្គលដែលនឹងក្លាយជាកូនសុំជាបុព្វញាតិរបស់បុគ្គល ដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម។ តាមការបកស្រាយក្នុង ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ បានលើកឡើងថា អាយុ ២៥ឆ្នាំ ត្រូវគិតចាប់ពីពេលដាក់ពាក្យសុំ ហេតុនេះករណីដែលអ្នកដាក់ពាក្យសុំមានអាយុ ២៥ឆ្នាំ នៅពេលដាក់ពាក្យសុំ តុលាការមិន

[១២]មាត្រា១០២០ កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី២០០៧

អាចបង្កើតសុំកូនធម្មតាបានទេ។ ដូច្នេះ បុគ្គលដែលអាចបង្កើតការសុំកូននោះឡើងបាន លុះត្រាតែមានអាយុត្រឹមត្រូវតាមច្បាប់ដែលបានចូលជាធរមានជាមុនសិន។

**២.១.២. ស្ថានភាព**

បុគ្គលដែលនឹងក្លាយជាឪពុក ឬ ម្ដាយចិញ្ចឹមនោះអាចជាបុគ្គលនៅលីវ ឬ ជាបុគ្គលដែលមានសហព័ទ្ធ ការដាក់ពាក្យសុំនៃសុំកូនធម្មតា ត្រូវមានការយល់ព្រមពីសហព័ទ្ធម្ខាងទៀត។ ម៉្យាងវិញទៀត បើកូនសុំជាអនីតិជន ការដាក់ពាក្យត្រូវធ្វើរួមគ្នាជាមួយនឹងសហព័ទ្ធម្ខាងទៀត ប៉ុន្តែបញ្ញត្តិនេះមិនត្រូវអនុវត្តឡើយ ចំពោះករណីដែលយកកូនសហព័ទ្ធមកធ្វើជាកូនសុំ ឬ ករណីដែលសហព័ទ្ធម្ខាងទៀតមិនអាចបង្ហាញឆន្ទៈបាន[១៣]។

**២.២. ចំពោះកូនសុំ**

**២.២.១ អាយុ**

អាយុរបស់កូនសុំធម្មតា ពុំត្រូវបានកម្រិតទេ ហេតុនេះ កូនសុំអាចជាអនីតិជន ឬ នីតិជន ហើយមានអាយុប៉ុន្មានក៏បានដែរ លើកលែងតែកូនសុំមានអាយុច្រើនជាងបុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹម ឬ កូនសុំនោះជាបុព្វញាតិរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹម[១៤]។

**២.២.២ ស្ថានភាពរបស់កូន**

សុំកូនធម្មតា អាចបង្កើតបានទោះបីជាបុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹមមាន ឬ គ្មានសហព័ទ្ធក៏ដោយ ប៉ុន្តែក្នុងករណីបុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹមមានសហព័ទ្ធដើម្បីបង្កើតសុំកូនធម្មតាបាន លុះត្រាតែមានការយល់ព្រមពីសហព័ទ្ធរបស់ខ្លួន[១៥]។ ប៉ុន្តែប្រសិនបើមានសហព័ទ្ធម្ខាង មិនបានដាក់ពាក្យជាមួយសហព័ទ្ធម្ខាងទៀត ឬ សហព័ទ្ធម្ខាងនោះមិនអាចបង្ហាញឆន្ទៈយល់ព្រមបាន សុំកូនធម្មតាក៏មិនអាចបង្កើតបានទេ[១៦]។ ដូចនេះ លុះត្រាតែមានការចូលរួមរវាងសហព័ទ្ធទាំងពីរ ទើបអាចបង្កើតសុំកូនបាន។

[១៣] មាត្រា១០២១ នៃក្រមរដ្ឋប្បវេណី២០០៧

[១៤] មាត្រា១០២០ កថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី២០០៧

[១៥] មាត្រា១០២២ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី២០០៧

[១៦] មាត្រា១០២២ វាក្យខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី២០០៧

ផ្ទុយទៅវិញ ក្នុងករណីដែលកូនសុំជាអនីតិជនហើយ បុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹមមានសហព័ទ្ធ ការយល់ព្រមរបស់ភាគីម្ខាងមិនគ្រប់គ្រាន់ទេ ពោលគឺត្រូវដាក់ពាក្យសុំរួមគ្នា (**សុំកូនដោយសហការ**) ទើបអាចបង្កើតសុំកូនធម្មតាបាន[១៧]។ ប៉ុន្តែ ក្នុងករណីយកកូនរបស់សហព័ទ្ធមកធ្វើជាកូនសុំ ឬ សហព័ទ្ធម្ខាងទៀតមិនអាចបង្ហាញឆន្ទៈបាន សុំកូនអាចបង្កើតឡើងបានត្រឹមអ្នកដាក់ពាក្យសុំតែម្នាក់ឯងប៉ុណ្ណោះ។

គួរបញ្ជាក់ថា ការដាក់ពាក្យសុំរួមគ្នា និង ការដាក់ពាក្យសុំដោយមានការយល់ព្រមពីសហព័ទ្ធមានភាពខុសគ្នាត្រង់ថាៈ ការដាក់ពាក្យសុំរួមគ្នា (ដូចមានចែងក្នុងមាត្រា ១០២១) សហព័ទ្ធទាំងពីរនឹងក្លាយជាឪពុកម្ដាយចិញ្ចឹម ប៉ុន្តែក្នុងករណីពាក្យសុំត្រូវបានដាក់ដោយសហព័ទ្ធម្ខាង ដោយមានការយល់ព្រមរបស់សហព័ទ្ធទៀត (ដូចមានចែងនៅក្នុងមាត្រា ១០២២) អ្នកដែលក្លាយជាឪពុកចិញ្ចឹម ឬ ម្ដាយចិញ្ចឹម គឺសហព័ទ្ធម្ខាងដែលបានដាក់ពាក្យសុំ។

តុលាការអាចបង្កើតសុំកូនធម្មតាបាន លុះត្រាតែករណីដែលអាចបង្ហាញពីឆន្ទៈពិតប្រាកដរបស់ភាគីក្នុងការបង្កើតទំនាក់ទំនងរវាងឪពុកម្ដាយនឹងកូន។ តុលាការមិនត្រូវបង្កើតឲ្យមានការសុំកូនឡើយ បើយល់ឃើញថាសុំកូនត្រូវបានបំពានក្នុងគោលបំណងរៀបអាពាហ៍ពិពាហ៍រវាងភេទផ្សេងគ្នា ឬភេទដូចគ្នា ឬ គោលបំណងមិនត្រឹមត្រូវផ្សេងទៀត[១៨]។ បើបុគ្គលដែលនឹងក្លាយជាកូនសុំជាអនីតិជនតុលាការអាចឲ្យបង្កើតសុំកូនបាន លុះត្រាតែយល់ឃើញថាមានភាពចាំបាច់ពិសេសដើម្បីផលប្រយោជន៍អនីតិជននោះ។ បើឪពុកម្ដាយរបស់អនីតិជននោះ បានលែងលះគ្នាហើយ តុលាការត្រូវសួរយោបល់របស់ឪពុកម្ដាយ ឬ ម្ដាយដែលមានអំណាចមេបាដើម្បីវិនិច្ឆ័យ។ បើអនីតិជនបានអាយុដល់ ១៥ (ដប់ប្រាំ)ឆ្នាំ ត្រូវមានការយល់ព្រមពីអនីតិជននោះសិន។ ទោះបីជាអនីតិជននោះមិនទាន់ដល់អាយុ ១៥ ឆ្នាំក៏ដោយ បើអនីតិជននោះអាចបង្ហាញឆន្ទៈរបស់ខ្លួនបាន តុលាការត្រូវសួរយោបល់របស់អនីតិជននោះដើម្បីវិនិច្ឆ័យ[១៩]។

---

[១៧]មាត្រា១០២១ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី២០០៧

[១៨]មាត្រា១០២៣ នៃក្រមរដ្ឋប្បវេណី២០០៧

[១៩]មាត្រា១០២៤ នៃក្រមរដ្ឋប្បវេណី២០០៧

ក្នុងករណីដែលអ្នកអាណាព្យាបាលសម្រាប់អនីតិជនដាក់ពាក្យឲ្យបង្កើតសុំកូន ដោយយកអនីតិជននៅក្រោមអាណាព្យាបាលរបស់ខ្លួនមកធ្វើជាកូនសុំ ឬ ករណីដែលអាណាព្យាបាលទូទៅដាក់ពាក្យសុំឲ្យបង្កើតសុំកូន បានលុះត្រាតែ ក្នុងករណីដែលបានអនុវត្តត្រឹមត្រូវ ក្នុងការគ្រប់គ្រងថែរក្សា នៅក្រោមអាណាព្យាបាល និងការគ្រប់គ្រងទ្រព្យសម្បត្តិ[២០]។

ក្នុងករណីបុគ្គលដែលនឹងក្លាយជាកូនសុំជានីតិជន ការដាក់ពាក្យបង្កើតសុំកូនធ្វើឡើងត្រឹមតែបុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម និង បុគ្គលដែលនឹងក្លាយជាកូនសុំនោះ ត្រូវមានភាពគ្រប់គ្រាន់ ដោយមិនពិចារណាអំពីឆន្ទៈរបស់ឪពុកម្តាយបង្កើតឡើយ។ ម៉្យាងវិញទៀត ទោះបីជាកូនសុំមានសហព័ទ្ធក៏ដោយ សុំកូនត្រូវបានបង្កើតឡើងត្រឹមឆន្ទៈរបស់កូនសុំ ដោយមិនពិចារណាអំពីឆន្ទៈរបស់សហព័ទ្ធនៃកូនសុំឡើយ។

ក្នុងករណីកូនសុំជាអនីតិជន សុំកូនអាចបង្កើតបានលុះត្រាតែមានការចូលរួមដាក់ពាក្យពីអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កូនសុំ ក្នុងនាមជាអ្នកមានអំណាចមេបា[២១]។ បើកូនសុំជាអនីតិជន មានអាយុដល់១៥ឆ្នាំ ដើម្បីបង្កើតសុំកូនបាន លុះត្រាតែមានការយល់ព្រមពីអនីតិជននោះ ហេតុនេះ ក្នុងករណីអនីតិជនមិនយល់ព្រម សុំកូនមិនអាចបង្កើតឡើងបានទេ[២២]។ តុលាការត្រូវធ្វើការវិនិច្ឆ័យអំពីការបង្កើតសុំកូនធម្មតា ដោយផ្អែកលើមូលដ្ឋានបីដូចជា **ទី១** ៖ តម្រូវឲ្យមានការបញ្ជាក់អំពីឆន្ទៈពិតប្រាកដរបស់ភាគី ក្នុងការបង្កើតទំនាក់ទំនងរវាងឪពុកម្តាយ និងកូន។ **ទី២** ៖ តុលាការមិនត្រូវបង្កើតឲ្យមានសុំកូនឡើយ បើយល់ឃើញថា បើសិនការសុំកូនត្រូវបានបំពានក្នុងគោលបំណងអាពាហ៍ពិពាហ៍ រវាងភេទផ្សេងគ្នា ឬ ដូចគ្នា ឬ ក្នុងគោលបំណងមិនត្រឹមត្រូវផ្សេងទៀត[២៣]។ **ទី៣** ៖ ក្នុងករណី កូនសុំជាអនីតិជន តុលាការអាចឲ្យបង្កើតធ្វើការសុំកូនបាន លុះត្រាតែយល់ឃើញថា មានភាពចាំបាច់ពិសេស ដើម្បីអត្ថប្រយោជន៍របស់កូនសុំដែលជា

[២០]មាត្រា១០០៨ នៃក្រមរដ្ឋប្បវេណី២០០៧

[២១]មាត្រា១០២០ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី២០០៧

[២២]មាត្រា១០២៤ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី២០០៧

[២៣]មាត្រា១០២៣ នៃក្រមរដ្ឋប្បវេណី២០០៧

អនីតិជននោះ[២៤]។ តុលាការ ត្រូវពិចារណាអំពីឆន្ទៈរបស់អនីតិជន កាលបើអនីតិជនមានអាយុដល់ ១៥ឆ្នាំ ហើយទោះបីជាពុំមានអាយុដល់១៥ (ដប់ប្រាំ) ឆ្នាំក៏ដោយ ក៏តុលាការអាចសួរយោបល់របស់អនីតិជនបានដែរ។ ម្យ៉ាងទៀត ក្នុងករណីឪពុកម្ដាយបង្កើតលែងលះគ្នា មុននឹងសម្រេចបង្កើតស្មុំកូនធម្មតា តុលាការត្រូវសួរយោបល់ឪពុក ឬ ម្ដាយបង្កើតដែលមិនមែនជាអ្នកមានអំណាចមេបា[២៥]។

[២៤]មាត្រា១០២៤ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី២០០៧
[២៥]មាត្រា១០២៤ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី២០០៧

# ជំពូកទី៣
# អានុភាព និងបញ្ហាចោទជុំវិញសុំកូន

## ផ្នែកទី១ ៖ អានុភាពទូទៅនៃសុំកូន

### ១.១. ចំពោះកូនសុំពេញលេញ

វាបានបញ្ជាក់ពីការបញ្ឈប់ក្នុងការគ្រប់គ្រងថែរក្សា និងកាន់កាប់ទាំងស្រុងជាស្ថាពរលើកូនសុំជាមួយគ្រួសារកំណើតរបស់កូនសុំ។ ការសុំកូនពេញលេញនេះ បានផ្តល់អានុភាពគតិយុត្តច្រើនជាងការសុំកូនធម្មតា ហើយឪពុកម្តាយចិញ្ចឹមត្រូវចាត់ទុកកូនសុំនោះជាកូនបង្កើតដោយផ្តល់សិទ្ធិ និងកាតព្វកិច្ចចំពោះកូនសុំដូចជាគុណសម្បត្តិនៃទាយាទបម្រុង ដូចនឹងបុព្វញាតិរបស់ឪពុកម្តាយចិញ្ចឹមដែរ។

#### ១.១.១. ការបញ្ចប់នូវញាតិភាពជាមួយនឹងឪពុកម្តាយបង្កើត

របបសុំកូនពេញលេញ មានគោលបំណងចិញ្ចឹមកុមារដែលបានសុំ ឲ្យទៅដូចជាកូនបង្កើតក្នុងមជ្ឈដ្ឋានគ្រួសារដែលមានស្ថិរភាពល្អ ដូច្នេះកូនសុំត្រូវស្ថិតនៅក្រោមការគ្រប់គ្រងទាំងស្រុងរបស់ឪពុកម្តាយចិញ្ចឹម។

បានសេចក្តីថា ការចូលជ្រៀតជ្រែក ឬ ការរំខានមិនសមស្របពីឪពុកម្តាយបង្កើត ដូចជាការទាមទារយកកូនមកវិញ ឬ ការទាមទារចចារជួបកូនជាដើម ត្រូវហាមឃាត់។ ម៉្យាងទៀត អំពើតាមទំនើងដូចជា ការទាមទារអាហារកាតព្វកិច្ចពីកូន នៅពេលដែលកូននោះពេញវ័យ ជាដើម ក៏ចាំបាច់ត្រូវដាក់ការរឹតត្បិតផងដែរ។ ហេតុនេះ សិទ្ធិធ្វើសន្តតិកម្មចំពោះគ្នាទៅវិញទៅមកត្រូវបានបាត់បង់ និងមិនអាចទទួលកាតព្វកិច្ចទៅវិញទៅមកបានទៀតទេ ហើយឪពុកម្តាយបង្កើតក៏ពុំមានសិទ្ធិសួរសុខទុក្ខកូនដែរ។

ក្រោយបង្កើតសុំកូន ញាតិភាពជាមួយឪពុកម្តាយបង្កើតត្រូវបានបញ្ចប់ មានន័យថា ឪពុកម្តាយ និងកូនបង្កើតក្លាយជាអ្នកដទៃលែងមានជាប់ទំនាក់ទំនងសាច់ឈាមជាមួយនឹងគ្នា ហើយញាតិលោហិតរបស់ឪពុកម្តាយបង្កើតក៏ត្រូវបញ្ចប់ដែរ លើកលែងតែក្នុងករណីកូនសុំជាកូនរបស់

សហាព័ន្ធម្ខាងទៀត[២៦]។ ម្យ៉ាងវិញទៀត ការបង្កើតស្មុំកូនពេញលេញ កុមារនឹងត្រូវរស់ក្នុងមជ្ឈដ្ឋានថ្មីនៃគ្រួសារឪពុកម្តាយចិញ្ចឹម។ ដូចនេះ ការគិតថាឪពុកម្តាយចិញ្ចឹម គឺជាឪពុកម្តាយបង្កើតរបស់ខ្លួន គឺជាភាពចាំបាច់ដើម្បីឲ្យទំនាក់ទំនងរវាងឪពុកម្តាយចិញ្ចឹម និង កូនសុំមានភាពសុខដុមរមនានឹងគ្នា។

ការបញ្ចប់ញាតិភាពជាមួយឪពុកម្តាយបង្កើត គឺជាមូលដ្ឋានសមរម្យ ទោះបីជា ទំនាក់ទំនងញាតិនេះត្រូវបានបញ្ចប់ដោយការកំណត់របស់ច្បាប់ក៏ដោយ ប៉ុន្តែញាតិភាពជាមួយឪពុកម្តាយបង្កើត និង ញាតិភាពជាមួយញាតិលោហិតរបស់ឪពុកម្តាយបង្កើត វាជាឈាមជ័រតាមធម្មជាតិ ហេតុនេះការហាមឃាត់រៀបអាពាហ៍ពិពាហ៍ជាមួយញាតិលោហិតនៅតែបន្ត[២៧]។ **ឧទាហរណ៍:** នៅពេលនាង **ធារី** នៅលីវគាត់បានមានទំនាក់ទំនងផ្លូវភេទជាមួយលោក **ហុង** រួចបង្កើតបានកូនម្នាក់ឈ្មោះ **សំណាង**។ លោក **ហុង** បានទទួលស្គាល់កូន **សំណាង** ដូច្នេះលោក **ហុង** ក្លាយទៅជាឪពុកបង្កើតរបស់ **សំណាង** (មាត្រា ៩៩៣ នៃក្រមរដ្ឋប្បវេណី) ។ តែលោក **ហុង** និងនាង **ធារី** ទាំងពីរនាក់ គ្មានសមត្ថភាពគ្រប់គ្រាន់ក្នុងការបីបាច់ថែរក្សា **សំណាង** ទេ។ លោក **សេង** និងនាង **បុប្ផា** ជាប្តីប្រពន្ធមានគោលបំណងសុំកូន **សំណាង** យកមកចិញ្ចឹមតាមរយៈស្មុំកូនពេញលេញ។ លោក **ហុង** និងនាង **ធារី** គឺជាឪពុកម្តាយបង្កើតរបស់ **សំណាង** បានផ្តល់ការយល់ព្រមអំពីការស្មុំកូនពេញលេញនេះ។ បន្ទាប់មកលោក **សេង** និងនាង **បុប្ផា** បានដាក់ពាក្យសុំឲ្យ បង្កើតស្មុំកូនពេញលេញទៅ តុលាការ។ តុលាការបានចេញដីកាសម្រេចដែលទទួលស្គាល់ស្មុំកូនពេញលេញដោយលោក **សេង** និងនាង **បុប្ផា**។ ដីកាសម្រេចនេះ បានចូលជាស្ថាពរហើយ។

ក្នុងករណីខាងនេះ ដោយសារបង្កើតស្មុំកូនពេញលេញបុត្តភាពរវាងកូន **សំណាង** និងឪពុកម្តាយបង្កើតត្រូវបានបញ្ចប់។ មានន័យថាមាតុភាពរវាងកូន **សំណាង** និងនាង **ធារី** ដែលជាម្តាយបង្កើតត្រូវបានបញ្ចប់។

ចំពោះបិតុភាពរវាងកូន **សំណាង** និងលោក **ហុង** គឺជាឪពុកបង្កើត ដែលបានកើតឡើងដោយការទទួលស្គាល់របស់លោក **ហុង** នោះក៏ត្រូវបញ្ចប់ផងដែរ។ម្យ៉ាងទៀត ដោយសារការបង្កើតស្មុំកូន

[២៦]មាត្រា១០១៤ នៃក្រមរដ្ឋប្បវេណី២០០៧
[២៧]មាត្រា៩៥១ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី២០០៧

ពេញលេញដដែលនេះ ញាតិភាពរវាងកូន **សំណាង** និងញាតិលោហិតរបស់លោក **ហុង** ត្រូវបានបញ្ចប់។ ញាតិភាព រវាងកូន **សំណាង** និងញាតិលោហិតរបស់នាង **ធារី** ក៏ត្រូវបញ្ចប់ផងដែរ។

ការបញ្ចប់នូវញាតិភាពរវាងកូន **សំណាង** និងឪពុកម្តាយបង្កើតព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយបង្កើតខាងលើនេះ នាំឲ្យមានអានុភាពផ្សេងៗដូចតទៅ៖

(១). សិទ្ធិ និងករណីយកិច្ចរបស់ឪពុកម្តាយបង្កើតដែលមិនរស់នៅជាមួយកូន (ក្រមរដ្ឋ-ប្បវេណី ឆ្នាំ២០០៧ មាត្រា ១០៤០)

(២). សិទ្ធិទាមទារឲ្យរាយការណ៍អំពីស្ថានភាពរបស់កូន (ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ១០៤១)

(៣). សិទ្ធិទាមទារឲ្យពិភាក្សាអំពីចំណុចសំខាន់ៗទាក់ទងទៅនឹងកូន (ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ១០៤២)

(៤). ករណីយកិច្ចត្រូវផ្គត់ផ្គង់អាហារកាតព្វកិច្ច និងសិទ្ធិទទួលអាហារកាតព្វកិច្ច (ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ១១៤០)

(៥). សិទ្ធិក្នុងការទទួលបន្តនូវមត៌កតាមសន្តតិកម្ម (ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ មាត្រា ១១៤៧)។

### ១.១.២. ការបង្កើតញាតិភាពជាមួយនឹងឪពុកម្តាយចិញ្ចឹម

ស្មុំកូនពេញលេញ គឺជាប្រព័ន្ធដែលមានបំណងគ្រប់គ្រងថែរក្សាកូនសុំ ដោយកក់ក្តៅ ដូចកូនបង្កើត នៅក្នុងគ្រួសាររបស់ឪពុកម្តាយចិញ្ចឹម ដូច្នេះ ឋានៈរបស់កូនសុំនោះ ត្រូវបានធានាឲ្យដូចជាកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹម។ ហេតុនេះ កូនសុំត្រូវទទួលបាននូវឋានៈដូចគ្នានឹងកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹម ហើយត្រូវមានសិទ្ធិ និង ករណីយកិច្ចដូចគ្នានឹងកូនបង្កើតផងដែរ[២៧]។ កូនសុំក៏មានសិទ្ធិទទួលអាហារកាតព្វកិច្ច ឬ សន្តតិកម្មពីឪពុកម្តាយចិញ្ចឹមផងដែរ។

លើសពីនេះ ឪពុកម្តាយចិញ្ចឹមត្រូវគ្រប់គ្រងថែរក្សាកូនសុំដោយភាពកក់ក្តៅ ការយកចិត្តទុកដាក់ខ្ពស់ ផ្តល់ការអប់រំ ឲ្យដូចជាកូនបង្កើតក្នុងគ្រួសារខ្លួន ។ ម្យ៉ាងវិញទៀត កូនសុំអាចប្រើនាម

[២៧]មាត្រា១០១៥ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី២០០៧

ត្រកូលរបស់ឪពុកម្ដាយចិញ្ចឹម ឬ នាមត្រកូលមុនសុំកូនក៏បានដែរ [២៩]។ កូនសុំត្រូវស្ថិតនៅក្រោមអំណាចមេបារបស់ឪពុកម្ដាយចិញ្ចឹម [៣០]។ ប៉ុន្តែ ក្នុងករណីដែលប្ដីប្រពន្ធណាម្ខាងក្លាយជាឪពុក ឬម្ដាយចិញ្ចឹមរបស់កូនបង្កើតនៃសហព័ទ្ធម្ខាងទៀត កូនសុំនោះត្រូវស្ថិតនៅក្រោមអំណាចមេបារួមរបស់ឪពុក ឬ ម្ដាយបង្កើត និង ឪពុកចិញ្ចឹម ឬ ម្ដាយចិញ្ចឹម។

ក្នុងករណីដែលសហព័ទ្ធម្ខាងសុំកូនដែលជាកូនបង្កើតរបស់សហព័ទ្ធម្ខាងទៀត ញាតិភាពរវាងកូនសុំ និង សហព័ទ្ធម្ខាងទៀតគឺជាឪពុក ឬ ម្ដាយបង្កើតរបស់កូនសុំ ព្រមទាំងញាតិលោហិតរបស់សហព័ទ្ធម្ខាងទៀតនោះ មិនត្រូវបញ្ចប់ដោយសុំកូនពេញលេញទេ (វាក្យខណ្ឌទី២ នៃមាត្រា ១០១៤ ក្រមរដ្ឋប្បវេណី)។ ដូច្នេះ សហព័ទ្ធម្ខាងទៀតនេះ នៅតែអាចគ្រប់គ្រងថែរក្សាកូននោះក្នុងនាមជាឪពុក ឬ ម្ដាយបង្កើតបាន។ ហេតុនេះហើយ កូនសុំនោះត្រូវស្ថិតនៅក្រោមអំណាចមេបារួមរបស់សហព័ទ្ធម្ខាងគឺជាឪពុកចិញ្ចឹម ឬ ម្ដាយចិញ្ចឹម និងសហព័ទ្ធម្ខាងទៀតគឺជាម្ដាយបង្កើត ឬ ឪពុកបង្កើត[៣១]។

ទំនាក់ទំនងរវាងកូនចិញ្ចឹម និង ឪពុកម្ដាយចិញ្ចឹមព្រមទាំងញាតិលោហិតរបស់ឪពុកម្ដាយចិញ្ចឹមនោះ នឹងត្រូវបង្កើតនូវញាតិភាព ដូចគ្នានឹងញាតិលោហិត គិតចាប់ពីថ្ងៃដែលបានសុំកូន។ មានន័យថា ទំនាក់ទំនងនៃឪពុកម្ដាយ និង កូនតាមច្បាប់ ត្រូវកើតឡើងរវាងឪពុកម្ដាយចិញ្ចឹម និងកូនសុំ ចាប់ពីថ្ងៃបង្កើតកូនសុំ។ ម៉្យាងទៀត ទំនាក់ទំនងញាតិភាពរវាងកូនសុំ និង ញាតិលោហិតរបស់ឪពុកម្ដាយចិញ្ចឹម ក៏ត្រូវកើតឡើងដែរ ដូចគ្នាទៅនឹងទំនាក់ទំនងញាតិភាពរវាងកូនបង្កើតរបស់ឪពុកម្ដាយចិញ្ចឹមនឹងញាតិលោហិតរបស់ឪពុកម្ដាយចិញ្ចឹមនោះ [៣២]។ ការកើតមានឡើងនូវទំនាក់ទំនងញាតិភាពដោយសុំកូនពេញលេញខាងលើនេះ នាំឲ្យមាន អានុភាពផ្សេងៗដូចតទៅ:

(១). សិទ្ធិធ្វើសន្តតិកម្ម (មាត្រា ១១៥៦ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី)

[២៩]មាត្រា១០១៥ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី២០០៧
[៣០]មាត្រា១០១៥ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី២០០៧
[៣១]មាត្រា១០១៥ កថាខណ្ឌទី៣ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី២០០៧
[៣២]មាត្រា៩៤០ នៃក្រមរដ្ឋប្បវេណី២០០៧

(២). សិទ្ធិទាមទារ និងករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ច (មាត្រា ១១៩០ នៃក្រមរដ្ឋប្បវេណី) ។

**ឧទាហរណ៍:** នៅពេលនាង **សុជាតា** នៅលីវនាងបានមានទំនាក់ទំនងផ្លូវភេទជាមួយនឹងលោក **សុធា** រួចបង្កើតបានកូនម្នាក់ឈ្មោះ **សុខា**។ លោក **សុធា** បានបដិសេធមិនទទួលស្គាល់កូននោះទេ។ ដូច្នេះនាង **សុជាតា** បានបន្តបីបាច់ថែរក្សាកូន **សុខា** ជាអ្នកមានអំណាចមេបា។ បន្ទាប់មកនាង **សុជាតា** បានរៀបការជាមួយលោក **វិសាល**។ លោក **វិសាល** ជាប្តីរបស់នាង **សុជាតា** មានគោលបំណងសុំកូន **សុខា** តាមរយៈសុំកូនពេញលេញ។ នាង **សុជាតា** គឺជាម្តាយបង្កើតរបស់ **សុខា** បានផ្តល់ការយល់ព្រមអំពីសុំកូនពេញលេញនោះ។ ដូច្នេះ លោក **វិសាល** បានដាក់ពាក្យសុំឲ្យបង្កើតសុំកូនពេញលេញ ទៅតុលាការ។ ហើយតុលាការបានចេញដីកាសម្រេចដែលទទួលស្គាល់សុំកូនពេញលេញដោយលោក **វិសាល**។ ដីកានេះសម្រេចចូលជាស្ថាពរហើយ។

ដូចនេះ ក្រោយពីសុំកូនពេញលេញនាង **សុជាតា** នៅតែអាចគ្រប់គ្រងថែរក្សាកូនក្នុងនាមជាម្តាយបង្កើតបានដដែល។ កូន **សុខា** ត្រូវស្ថិតនៅក្រោមអំណាចមេបារួមរបស់នាង **សុជាតា** គឺជាម្តាយបង្កើត និងលោក **វិសាល** គឺជាឪពុកចិញ្ចឹម។

### ១.២. ចំពោះកូនសុំធម្មតា

#### ១.២.១. ការបន្តញាតិភាពជាមួយឪពុកម្តាយបង្កើត

ក្រោយពេលបានបង្កើតសុំកូនធម្មតា បុគ្គភាពរវាងកូនសុំ និង ឪពុកម្តាយបង្កើតត្រូវបន្តអត្ថិភាព ។ ហេតុនេះកូនសុំ និង ឪពុកម្តាយបង្កើត មានសិទ្ធិក្នុងការធ្វើសន្តតិកម្មឲ្យគ្នាទៅវិញទៅមក ហើយក៏មានសិទ្ធិទាមទារ និង ករណីយកិច្ចផ្គត់ផ្គង់អាហារកាតព្វកិច្ចចំពោះគ្នាទៅវិញទៅមកផងដែរ[៣៣]។ ជាទូទៅ សុំកូនធម្មតា កូនសុំនោះមានឪពុកម្តាយបង្កើតផង និង ឪពុកម្តាយចិញ្ចឹមផង ហេតុដូចនេះ សិទ្ធិក្នុងការធ្វើសន្តតិកម្ម ក៏មានចំពោះគ្នាទៅវិញទៅមកដែរ មានន័យថា មានទាំងទំនាក់ទំនងជាមួយឪពុកម្តាយចិញ្ចឹម និងឪពុកម្តាយបង្កើត ប៉ុន្តែទោះបីជា យ៉ាងណាក៏ដោយក្នុងករណីកូនសុំជាអនីតិជន អ្នកដែលមានអំណាចមេបាលើកូនសុំ គឺឪពុកម្តាយចិញ្ចឹម។

[៣៣]មាត្រា១០២៦ នៃក្រមរដ្ឋប្បវេណី២០០៧

### ១.២.២. ការបង្កើតញាតិភាពជាមួយឪពុកម្ដាយចិញ្ចឹម

បន្ទាប់ពីបង្កើតសុំកូនរួចមក ញាតិភាពរវាងឪពុកម្ដាយចិញ្ចឹម និងកូនសុំត្រូវបានបង្កើតឡើង កូនសុំមានឋានៈដូចគ្នាទៅនឹងកូនបង្កើតដែរ ហើយមានសិទ្ធិធ្វើសន្តតិកម្ម និង កាតព្វកិច្ចចំពោះគ្នាទៅវិញទៅមកផងដែរ ហើយកូនសុំអាចប្រើប្រាស់នាមត្រកូលរបស់ឪពុកម្ដាយចិញ្ចឹម ឬ នាមត្រកូលរបស់ខ្លួនមុនពេលបង្កើតសុំកូនបាន [៣៤] ។ ក្នុងករណី ដែលកូនសុំនោះជាអនីតិជន កូនសុំត្រូវស្ថិតក្រោមអំណាចមេបារបស់ឪពុកម្ដាយចិញ្ចឹម ឪពុក ឬ ម្ដាយចិញ្ចឹម ប៉ុន្តែក្នុងករណី យកកូនបង្កើតរបស់សហព័ទ្ធមកធ្វើជាកូនសុំ កូនសុំនោះត្រូវស្ថិតក្រោមអំណាចមេបារួមរបស់ឪពុក ឬ ម្ដាយចិញ្ចឹម និងសហព័ទ្ធនោះ[៣៥]។

ក្នុងករណីសុំកូនធម្មតា ទំនាក់ទំនងរវាងឪពុកម្ដាយបង្កើត និងកូនសុំ និងទំនាក់ទំងរវាងឪពុកម្ដាយចិញ្ចឹម និងកូនសុំ មានអត្ថិភាពព្រមគ្នា។ ដូច្នេះហើយ វាមានភាពចាំបាច់ក្នុងការសម្រេចថា ឪពុកម្ដាយបង្កើត ឬ ឪពុកម្ដាយចិញ្ចឹម ជាអ្នកដែលមានអំណាចមេបា។ ដោយសារសុំកូនដែលជាអនីតិជន មានគោលបំណងយកកូននោះទៅបីបាច់ថែរក្សាដោយផ្ទាល់ ឪពុកម្ដាយចិញ្ចឹម គួរតែជាអ្នកមានអំណាចមេបាទៅលើកូនសុំនោះ។ ដូច្នេះ អ្នកដែលមានអំណាចមេបាលើកូនសុំគឺ ឪពុកម្ដាយចិញ្ចឹម[៣៦]។

## ផ្នែកទី២ ៖ បញ្ហាចោទចំពោះកូនសុំ

### ២.១.ការកាត់កាល់

នៅក្នុងក្រមរដ្ឋប្បវេណីមិនបានឲ្យនិយមន័យទៅលើការកាត់កាល់នោះទេ តែបើក្រឡេកមើលក្នុងវចនានុក្រមខ្មែររបស់សម្ដេចព្រះសង្ឃរាជ **ជួន ណាត** បានកំណត់ថា **កាត់កាល់** (កិ.): បោះបង់លែងរាប់អានតទៅ។

[៣៤]មាត្រា១០២៧ កថាខណ្ឌទី១ និងទី២ នៃក្រមរដ្ឋប្បវេណី២០០៧
[៣៥]មាត្រា១០២៧ កថាខណ្ឌទី៣ នៃក្រមរដ្ឋប្បវេណី២០០៧
[៣៦]មាត្រា១០៣៥ នៃក្រមរដ្ឋប្បវេណី២០០៧

### ២.១.១. ចំពោះសុំកូនពេញលេញ

#### ២.១.១.១. មូលហេតុ និងការវិនិច្ឆ័យការកាត់កាល់

សុំកូនពេញលេញ មានបំណងផ្តល់នូវការគ្រប់គ្រងថែរក្សាដូចជាកូនបង្កើត ដូច្នេះជាគោលការណ៍ការកាត់កាល់មិនត្រូវបានទទួលស្គាល់ឡើយ។ ក៏ប៉ុន្តែ ក្នុងករណីដែលការបន្តទំនាក់ទំនងសុំកូនធ្វើឲ្យកុមារមានការរងគ្រោះ ដោយអំពើផ្សេងៗ ឬ ប៉ះពាល់ធ្ងន់ធ្ងរដល់អត្ថប្រយោជន៍កូនសុំ ឬក៏ករណីដែលអាចរំពឹងបាននូវការគ្រប់គ្រងថែរក្សាដោយត្រឹមត្រូវពីឪពុកម្តាយបង្កើត កូនសុំអាចធ្វើបណ្តឹងទាមទារនៃការកាត់កាល់បាន។ មិនចំពោះតែ ក្នុងករណីនេះប៉ុណ្ណោះទេ ដែលអាចជាមូលហេតុនៃបណ្តឹងទាមទារនៃការកាត់កាល់ គឺនៅមានមូលហេតុដទៃទៀត ក៏អាចធ្វើបណ្តឹងទាមទារបានដែរដោយអាស្រ័យទៅលើឆន្ទានុសិទ្ធិរបស់តុលាការ។

ប្រសិនបើ ឪពុកម្តាយបង្កើតមានលទ្ធភាពគ្រប់គ្រាន់ក្នុងការថែរក្សាកូនបានឡើងវិញ នៅក្នុងករណីមួយនេះ ឪពុកម្តាយបង្កើតមិនអាចសុំកាត់កាល់កូនសុំពីឪពុកម្តាយចិញ្ចឹម ដោយសំអាងលើលទ្ធភាពរបស់ខ្លួនបាននោះទេ។

ទំនាក់ទំនងរវាងឪពុកម្តាយចិញ្ចឹម និង កូនសុំទោះបីមិនមែនជាកូនបង្កើតក៏ដោយ ប៉ុន្តែវាមានលក្ខណៈដូចជាកូនបង្កើតដែរ ហេតុនេះ ឪពុកម្តាយចិញ្ចឹម និង កូនសុំ ក៏មិនអាចបញ្ចប់ទំនាក់ទំនងនឹងគ្នាដោយងាយស្រួលដែរ។ ទោះបីជាយ៉ាងណាក៏ដោយ សុំកូនគ្រាន់តែជាការសន្មតរបស់ច្បាប់តែប៉ុណ្ណោះ វានៅតែមិនមែនជាកូនបង្កើត ហេតុនេះ សុំកូនអាចបញ្ចប់បានតាមរយៈការកាត់កាល់ដោយស្ថិតនៅក្រោមលក្ខខណ្ឌយ៉ាងតឹងរឹងដូចមានចែងនៅក្នុងមាត្រា ១០១៦ នៃក្រមរដ្ឋប្បវេណី ២០០៧។

#### ២.១.១.២. លក្ខខណ្ឌនៃការកាត់កាល់សុំកូនពេញលេញ

ការកាត់កាល់ ត្រូវធ្វើឡើងតាមផ្លូវតុលាការតែប៉ុណ្ណោះដោយធ្វើបណ្តឹងទាមទារឲ្យកាត់កាល់ ហើយការសម្រេចអំពីការកាត់កាល់ ត្រូវអនុលោមតាមច្បាប់ស្តីពីនីតិវិធីនៃបណ្តឹងទាក់ទងនឹងឋានៈបុគ្គល[៣៧]។ បុគ្គលដែលអាចធ្វើបណ្តឹងទាមទារឲ្យកាត់កាល់បានមានតែ៖ **ទី១** កូនសុំ **ទី២** ឪពុកម្តាយបង្កើត **ទី៣** តំណាងអយ្យការប៉ុណ្ណោះ ដោយផ្អែកលើមូលហេតុនៃការកាត់កាល់ដែលកំណត់ដោយ

[៣៧]មាត្រា៣ ចំណុច ៨ នៃនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល

ច្បាប់ ហេតុនេះទោះបីជាមានមូលហេតុបែបណាក៏ដោយ ឪពុកម្តាយចិញ្ចឹមមិនអាចកាត់កាល់កូនសុំបានទេ។

បើយល់ឃើញថា មានភាពចាំបាច់ពិសេស ដើម្បីផលប្រយោជន៍របស់កូនសុំ តុលាការអាចកាត់កាល់ភាគីកូនសុំបាន តាមពាក្យសុំតាមរយៈអ្នកមានសិទ្ធិប្តឹងកាត់កាល់ទាំងបីខាងលើ ដោយមានករណីមួយចំនួនដូចជា:

- មានការធ្វើបាបដោយឪពុកម្តាយចិញ្ចឹម បោះបង់កូនសុំចោលដោយគំនិតទុច្ចរិត ឬហេតុផ្សេងៗទៀតដែលបំពានផលប្រយោជន៍របស់កូនសុំយ៉ាងធ្ងន់ធ្ងរ។
- ឪពុកម្តាយបង្កើតអាចគ្រប់គ្រងថែរក្សាដោយសមរម្យបាន។
- តុលាការយល់ឃើញថា ការកាត់កាល់សុំកូនពេញលេញនេះ មានភាពចាំបាច់ពិសេសដើម្បីផលប្រយោជន៍របស់កូនសុំ។

ដូច្នេះ ទាល់តែមាននូវគ្រប់លក្ខខណ្ឌខាងលើទើបតុលាការអាចធ្វើការកាត់កាល់ភាគីកូនសុំបាន[៣៨]។

### ២.១.១.៣. អានុភាពនៃការកាត់កាល់សុំកូនពេញលេញ

នៅពេលកិច្ចសន្យាសុំកូនត្រូវបានរលត់ដោយការកាត់កាល់នេះ វាបណ្តាលឲ្យមានអានុភាពផ្សេងៗចំពោះភាគីទាំងសងខាងនៃកិច្ចសន្យានេះ ពោលគឺឪពុកម្តាយចិញ្ចឹម និង កូនសុំ។ ញាតិភាពរវាងកូនចិញ្ចឹម សហព័ទ្ធរបស់ជននោះ បច្ឆាញាតិផ្ទាល់ និង សហព័ទ្ធរបស់បច្ឆាញាតិផ្ទាល់នោះជាមួយឪពុកម្តាយចិញ្ចឹម និងញាតិលោហិតរបស់ឪពុកម្តាយចិញ្ចឹមនោះ ត្រូវបានបញ្ចប់ដោយការកាត់កាល់ ឬ លែងទទួលស្គាល់[៣៩]។ អានុភាពមួយផ្សេងទៀត គឺញាតិភាពរវាងកូនសុំ និង ឪពុកម្តាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយបង្កើតនោះ ដែលបានបញ្ចប់ដោយសុំកូនពេញលេញត្រូវបានកើតឡើងវិញចាប់ពីថ្ងៃកាត់កាល់នោះ។

ជារួម នៅពេលកាត់កាល់សុំកូនពេញលេញបណ្តាលឲ្យមានអានុភាពពីរយ៉ាងគឺ **ទី១** បណ្តាលឲ្យញាតិភាពរវាងកូនសុំ និង ឪពុកម្តាយចិញ្ចឹម ក៏ដូចជាញាតិលោហិតរបស់ឪពុកម្តាយនោះត្រូវបាន

[៣៨]មាត្រា១០១៦ នៃក្រមរដ្ឋប្បវេណី២០០៧
[៣៩]មាត្រា៩៩២ នៃក្រមរដ្ឋប្បវេណី២០០៧

បញ្ចប់។ **ទី២** ញាតិភាពរវាងកូន និង ឪពុកម្តាយបង្កើត ក៏ដូចជាញាតិលោហិតរបស់ឪពុកម្តាយបង្កើត ដែលពីមុនបានបញ្ចប់ ដោយសុំកូនពេញលេញត្រូវបានបង្កើតឡើងដោយការកាត់កាល់នោះ។

នៅពេលដែលសុំកូនពេញលេញ ត្រូវបានរំលាយដោយការកាត់កាល់ត្រូវបង្កើតឡើងវិញ ដោយស្វ័យប្រវត្តិនូវបុត្តភាពរវាងកូនសុំ និង ឪពុកម្តាយបង្កើតដែលត្រូវបានបញ្ចប់ដោយការបង្កើតសុំកូនពេញលេញនោះ។ ម៉្យាងទៀត ញាតិភាពរវាងកូនសុំ និង ញាតិលោហិតរបស់ឪពុកម្តាយបង្កើតក៏ត្រូវកើតឡើងវិញដោយស្វ័យប្រវត្តិផងដែរ នៅពេលកាត់កាល់សុំកូនពេញលេញនោះ[៩០]។

### ២.១.២. ចំពោះសុំកូនធម្មតា

#### ២.១.២.១. មូលហេតុ និងការវិនិច្ឆ័យការកាត់កាល់

ការកាត់កាល់ គឺត្រូវបានប្រើលើគ្រប់សុំកូនបានទាំងអស់ ឲ្យតែអនុវត្តតាមច្បាប់ ដែលបានបញ្ញត្តិជាធរមាន។ ការកាត់កាល់ គឺជាការបោះបង់លែងរាប់អានតទៅទៀត មានន័យថា បើមានពាក្យសុំកាត់កាល់សុំកូនធម្មតា តុលាការអាចសម្រេចឲ្យកាត់កាល់បាន លុះត្រាតែបានបញ្ជាក់ថាភាគីទាំងសងខាង មានបំណងពិតប្រាកដក្នុងការរំលាយទំនាក់ទំនងរវាងឪពុកម្តាយ និង កូន។ បុគ្គលដែលអាចដាក់ពាក្យបណ្តឹងទាមទារឲ្យកាត់កាល់បាន លុះត្រាតែភាគីម្ខាងទៀតបានប្រព្រឹត្តក្នុងករណីដូចបញ្ញត្តិខាងក្រោមដែលបានចែងក្នុងមាត្រា១០៣១ នៃក្រមរដ្ឋប្បវេណី២០០៧ ៖

១. បើត្រូវបានបោះបង់ចោលដោយភាគីម្ខាងទៀតដោយទុច្ចរិត

២. បើមិនច្បាស់ក្នុងអំឡុងពេលយ៉ាងតិច ១ឆ្នាំ ថាភាគីម្ខាងទៀតនៅរស់ ឬ ទទួលមរណភាព

៣. បើមានមូលហេតុធ្ងន់ធ្ងរផ្សេងទៀត ដែលបណ្តាលឲ្យមានការពិបាកក្នុងការបន្តសុំកូននេះ ដូចជាអំពើហិង្សា ទារុណកម្ម ការជេរប្រមាថ ការប្រព្រឹត្តិអំពើមិនត្រឹមត្រូវធ្ងន់ធ្ងរគួរឲ្យកត់សម្គាល់ ជាអាទិ៍ដែលធ្វើឲ្យទំនាក់ទំនងសុំកូនវិនាស និងមិនអាចរំពឹងថានឹងស្តារឡើងវិញបាន។

#### ២.១.២.២. ពាក្យសុំឲ្យកាត់កាល់សុំកូនធម្មតា

[៩០]មាត្រា១០១៧ នៃក្រមរដ្ឋប្បវេណី២០០៧

ភាគីនៃកូនសុំ អាចដាក់ពាក្យសុំទៅតុលាការឲ្យកាត់កាល់សុំកូនធម្មតាបាន ក្នុងករណីដែលភាគីទាំងសងខាងព្រមព្រៀងអំពីការកាត់កាល់នោះ តែប្រសិនបើក្នុងករណីដែលកូនសុំជាអនីតិជន ពាក្យកាត់កាល់ដែលបានធ្វើឡើងដោយមានការព្រមព្រៀងគ្នានោះ ត្រូវធ្វើឡើងដោយឪពុកម្តាយចិញ្ចឹម និង បុគ្គលដែលនឹងត្រូវក្លាយជាអ្នកតំណាង ដែលច្បាប់បានកំណត់ក្រោយពេលកាត់កាល់ តែបើកូនសុំដល់អាយុ ១៥ (ដប់ប្រាំ)ឆ្នាំ ហើយត្រូវទទួលការយល់ព្រមពីកូនសុំនោះ។ តែទោះបីជាយ៉ាងណាក៏ដោយ អនីតិជននោះមិនទាន់ដល់អាយុ១៥ឆ្នាំក៏ដោយ បើអនីតិជននោះអាចបង្ហាញឆន្ទៈរបស់ខ្លួន តុលាការត្រូវសួរយោបល់របស់អនីតិជននោះ។ ក្នុងករណីដែលឪពុកម្តាយបង្កើតរបស់កូនសុំបានលែងលះគ្នាហើយ ឪពុកម្តាយបង្កើតរបស់កូនសុំនោះត្រូវពិភាក្សា និង កំណត់ថាឪពុក ឬ ម្តាយបង្កើតជាបុគ្គលដែលត្រូវក្លាយជាអ្នកមានអំណាចមេបានៅក្រោយពេលកាត់កាល់ បើសិនជា ការពិភាក្សាខាងលើពុំបានសម្រេច ឬ ពុំអាចពិភាក្សាបានទេ តុលាការត្រូវកំណត់បុគ្គលដែលត្រូវក្លាយជាអ្នកមានអំណាចមេបា ដោយគិតពិចារណាទៅលើផលប្រយោជន៍របស់កូនសុំ[៥១]។

**២.១.២.៣. លក្ខខណ្ឌនៃការកាត់កាល់សុំកូនធម្មតា**

ដើម្បីឲ្យកាត់កាល់សុំកូនធម្មតាប្រព្រឹត្តិទៅបាន លុះត្រាតែមានមូលហេតុដូចជា៖

ភាគីម្ខាងនៃសុំកូន អាចដាក់ពាក្យបណ្តឹងទាមទារឲ្យកាត់កាល់បាន លុះត្រាតែ បើត្រូវបានបោះបង់ចោលដោយភាគីម្ខាងទៀតដោយទុច្ចរិត។ បើមិនច្បាស់ ក្នុងអំឡុងពេលយ៉ាងតិច ១ (មួយ) ឆ្នាំ ថាភាគីម្ខាងទៀតនៅរស់ ឬ ទទួលមរណភាព។ បើមានហេតុធ្ងន់ធ្ងរផ្សេងទៀត ដែលបណ្តាលឲ្យមានការពិបាកក្នុងការបន្តសុំកូន។

ក្នុងអំឡុងពេលដែលកូនសុំពុំទាន់ក្លាយជានីតិជន ឪពុកម្តាយចិញ្ចឹមមិនអាចដាក់ពាក្យបណ្តឹងសុំកាត់កាល់ចំពោះកូនសុំបានឡើយ។

ទោះបីក្នុងករណីកូនសុំជាអនីតិជនក៏ដោយ ក៏កូនសុំអាចដាក់ពាក្យបណ្តឹងចំពោះឪពុកម្តាយចិញ្ចឹមបានដែរ ឲ្យតែបានគោរពលក្ខខណ្ឌដូចដែលបានកំណត់ខាងលើ[៥២]។

**២.១.២.៤. អានុភាពនៃការកាត់កាល់សុំកូនធម្មតា**

[៥១]មាត្រា១០២៨ នៃក្រមរដ្ឋប្បវេណី២០០៧

[៥២]មាត្រា១០៣១ នៃក្រមរដ្ឋប្បវេណី២០០៧

អានុភាពទាំងឡាយនៃសុំកូនធម្មតា ត្រូវបញ្ចប់ទៅអនាគតដោយការកាត់កាល់ ហើយក្រោយការកាត់កាល់កូនសុំអាចទទួលបានវិញនូវនាមត្រកូលមុនសុំកូនក៏បាន ឬ អាចប្រើត្រកូលរបស់ឪពុកម្តាយចិញ្ចឹមក៏បាន។

## ២.២. ការបោះបង់កូនសុំចោល

### ២.២.១. ឪពុកម្តាយសុំ

កត្តាដែលនាំឲ្យមានការបោះបង់ចោលកូនសុំនេះ គឺបណ្តាលមកពីអំពើអសីលធម៌របស់កូនសុំដែលប្រព្រឹត្តទង្វើមិនគប្បី ឬ អំពើមិនសមរម្យទៅលើឪពុកម្តាយសុំ ដែលជាហេតុនាំឲ្យឪពុកម្តាយសុំនោះ មិនអាចទទួលយកនូវអ្វីដែលកូនសុំនោះបានធ្វើ ដូចនេះ ទើបបង្កអោយមានការបោះបង់កូនសុំនោះចោល។

### ២.២.២. កូនសុំ

មូលហេតុដែលនាំឲ្យមានការបោះបង់ឪពុកម្តាយសុំចោល គឺបណ្តាលមកពីអំពើអសីលធម៌ ឬ ធ្វើបាបកូនសុំនោះ ដោយប្រើប្រាស់ ធ្វើបាបកូនសុំនោះ ដើម្បីជាផលប្រយោជន៍របស់ខ្លួន។

## ផ្នែកទី៣ ៖ ទោសទណ្ឌ

ជាទូទៅទោសទណ្ឌ តែងតែភ្ជាប់មកជាមួយនូវច្បាប់ដែលរៀបចំសណ្តាប់ធ្នាប់នៅក្នុងសង្គម និង ដើម្បីបង្កើននូវប្រសិទ្ធិភាព និង អានុភាពនៃច្បាប់នោះ។ ការធ្វើបែបនេះ គឺសុទ្ធតែដើម្បីបង្ការ និង បញ្ចៀសនូវរាល់វិការៈណាមួយដែលកើតឡើងក្នុងដំណើរការនៃច្បាប់។ ទោសទណ្ឌ គឺទាមទារស្វែងរកនូវយុត្តិធម៌ និង ព្រមានជៀសវាងអំពើផ្តាំផ្តួងម្តងហើយ ម្តងទៀត ព្រមទាំងធ្វើយ៉ាងណាដើម្បីឲ្យការអនុវត្តក្នុងដំណើរស្របទៅតាមច្បាប់ដែលបានកំណត់។

ជាគោលការណ៍នៅគ្រប់ករណី នៃបទល្មើសទាំងឡាយនឹងទទួលរងនូវទណ្ឌកម្មព្រហ្មទណ្ឌ ឬ ទណ្ឌកម្មរដ្ឋប្បវេណី ឬ អាចទទួលរងទណ្ឌកម្មព្រហ្មទណ្ឌផង និង សំណងរដ្ឋប្បវេណីផង ឬ ការប្រកាសនូវទោសផ្សេងៗទៀត អាស្រ័យទៅតាមស្ថានទម្ងន់ទោសរបស់ជនល្មើស។

- ទណ្ឌកម្មព្រហ្មទណ្ឌ: ទោសដាក់ពន្ធនាគារ
- ទណ្ឌកម្មរដ្ឋប្បវេណី: ទោសពិន័យជាប្រាក់

- ទោសដាក់ពន្ធនាគារផង និង ទោសពិន័យជាប្រាក់ហើយរួមទាំងការប្រកាសនូវទោសបន្ថែម[៤៣]គឺ:
  - ការដកសិទ្ធិខ្លះជាពលរដ្ឋ សម្រាប់រយៈពេលយ៉ាងច្រើន ៥ (ប្រាំ) ឆ្នាំ។
  - ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស សម្រាប់រយៈពេលយ៉ាងច្រើន ២ (ពីរ) ខែ[៤៤]។
  - ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងទំព័រសារព័ត៌មាន។
  - ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមរយៈគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល ៨ (ប្រាំបី) ថ្ងៃយ៉ាងច្រើន។

ការនាំយកអនីតិជន ឬ ជនដែលនៅក្រោមអាណាព្យាបាលទូទៅ ឬ នៅក្រោមហិតូបត្ថម្ភ ឬ នៅក្រោមអ្នកគ្រប់គ្រងស្របច្បាប់ ដោយគ្មានអំណាចតាមផ្លូវច្បាប់ ឬ យុត្តិកម្មតាមផ្លូវច្បាប់ចេញពីការគ្រប់គ្រងស្របច្បាប់នៃឪពុកម្តាយ អ្នកថែរក្សា ឬ អ្នកអាណាព្យាបាលរបស់គេ[៤៥]។

ចំពោះអំពើលក់ដូរមនុស្ស មានន័យថា ការប្រគល់ឲ្យដោយខុសច្បាប់ នូវការគ្រប់គ្រងលើជនណាម្នាក់ទៅជនដទៃ ឬ ទទួលយកដោយខុសច្បាប់ នូវការប្រគល់ការគ្រប់គ្រងលើជនណាម្នាក់ពីជនដទៃ ដោយដោះដូរទៅនឹងរបស់មានតម្លៃអ្វីមួយ ដោយរាប់បញ្ចូលទាំងសេវា និង មនុស្សផង។ អំពើធ្វើជាភ្នាក់ងារកណ្តាលនៃការលក់-ដូរមនុស្ស ត្រូវផ្តន្ទាទោសដូចគ្នានឹងចារីដែរ[៤៦]។

[៤៣]មាត្រា៥៣ នៃក្រមព្រហ្មទណ្ឌ២០០៩
[៤៤]មាត្រា៦៨ នៃក្រមព្រហ្មទណ្ឌ២០០៩
[៤៥]មាត្រា៨ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ
[៤៦]មាត្រា១៣ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីធ្វើការបកស្រាយតាមការសិក្សាស្រាវជ្រាវដំណើរការនៃនីតិវិធីសុំកូន និង បញ្ហានានាទាក់ទងនឹងការសុំកូនខាងលើនេះមក បញ្ជាក់ឃើញថា គ្រប់លក្ខខណ្ឌគឺក្នុងគោលបំណងមនុស្សធម៌។ កត្តានេះហើយ ដែលជាជំរុញឲ្យរាជរដ្ឋាភិបាលមានការបង្កើត ច្បាប់ អនុក្រឹត្យ ប្រកាស ឬ សារាចរណ៍ណែនាំផ្សេងៗ និង សហការជាមួយក្រសួងដែលជាស្ថាប័នពាក់ព័ន្ធនានា ដើម្បីធានាដល់ ការការពារសិទ្ធិជាមូលដ្ឋាន និង ជាឧត្តមប្រយោជន៍កុមារជាធំ។

ជនដែលមានបំណងចង់បានកុមារ យកធ្វើជាកូនចិញ្ចឹមគឺត្រូវគោរពតាមលក្ខខណ្ឌដែលស្មុគស្មាញមុននឹងទទួលបានសិទ្ធិធ្វើជាអាណាព្យាបាល និង ឪពុកម្តាយកុមារនោះ។ ដោយឡែក សុំកូនពេញលេញ គឺមានលក្ខណៈខុសពីសុំកូនធម្មតា។ ដោយមានសុំកូនពេញលេញមានលក្ខណៈតឹងរឹង និងស្មុគស្មាញ ដែលមានការផ្តាច់ចំណងញាតិភាពរវាងកូនសុំ និង ឪពុកម្តាយបង្កើត ហើយអំណាចមេបាគឺបានទៅលើឪពុកម្តាយចិញ្ចឹមទាំងស្រុង។ ចំពោះកូនសុំធម្មតា គឺមានលក្ខណៈងាយស្រួលជាង ព្រោះកូនសុំមិនត្រូវបានកាត់ផ្តាច់លើចំណងញាតិភាពរវាងកូនសុំ និង ឪពុកម្តាយបង្កើតឡើយ។ ដូច្នេះ រាល់ការសុំកូនទាំងឡាយត្រូវតែធ្វើឡើងតាមរយៈនីតិវិធីនៃសុំកូនដែលបានកំណត់ដោយច្បាប់។

សុំកូនក្នុងប្រទេស ដែលយោងតាមក្រមរដ្ឋប្បវេណី ពុំសូវជាមានបញ្ហាចោទប៉ុន្មាននោះទេ ដោយសារនីតិវិធីមិនសូវតឹងរឹង ហើយកូនសុំត្រូវបានរស់នៅក្នុងប្រទេសកម្ពុជាដដែលគ្រាន់តែស្ថិតនៅក្រោមការគ្រប់គ្រង ឬ អំណាចមេបារបស់ឪពុកម្តាយចិញ្ចឹមទាំងស្រុង។ រាល់ការសុំកូនដែលប្រព្រឹត្តឡើងតាមនីតិវិធីច្បាប់គឺជារឿងចាំបាច់ ដើម្បីជៀសវាងបញ្ហា ដែលអាចប៉ះពាល់ដល់អនាគតរបស់កុមារ និង ជាពិសេសលើការជួញដូរកុមារ។

ទោះបីជា នីតិវិធីនៃដំណើរការសុំកូនត្រូវបានបញ្ចប់ក៏ពិតមែន ប៉ុន្តែមិនមែនបានន័យថា ចប់រាល់បញ្ហាដែលទាក់ទងនឹងកូនសុំទាំងអស់នោះទេ។ បន្ទាប់ពីចប់នីតិវិធីនៃសុំកូន កូនសុំត្រូវធានាថាទទួលបានឋានៈ សិទ្ធិ និង ករណីយកិច្ចដូចគ្នានឹងកូនបង្កើតដែរ។ មានន័យថា កូនចិញ្ចឹមត្រូវបានឪពុកម្តាយចិញ្ចឹមទទួលស្គាល់ និង គិតគូរពីអនាគតដូចកូនបង្កើតរបស់ខ្លួន។ កូនសុំត្រូវទទួលបានសិទ្ធិថែទាំជាអចិន្ត្រៃយ៍ ទាំងផ្នែកសុខភាព អនាម័យ សម្លៀកបំពាក់ និង ចំណីអាហារ ការអភិវឌ្ឍ

ផ្នែកសង្គម និង វប្បធម៌។ ពិសេសកូនសុំ ក៏ទទួលបានការសិក្សាអប់រំជាចំបង ការទូន្មានប្រៀនប្រដៅ និងភាពកក់ក្តៅពីឪពុកម្តាយចិញ្ចឹមគ្រប់ពេលវេលា។ ម៉្យាងទៀតត្រូវតែជានាលើឧត្តមប្រយោជន៍របស់កុមារប្រកបដោយសុភមង្គល ភាពថ្លៃថ្នូរ និង អនាគតរបស់កុមារពោរពេញទៅដោយភាពរុងរឿងត្រចះត្រចង់។

# អនុសាសន៍

យោងទៅតាមរយៈការសិក្សាស្រាវជ្រាវកន្លងមករបស់ខ្ញុំផ្ទាល់ ការសុំកូននៅក្នុងប្រទេសគឺមានភាពមិនប្រក្រតីជាច្រើន ដូចជាឪពុកម្តាយចិញ្ចឹមមួយចំនួន គាត់បានធ្វើការសុំកូនដោយមធ្យោបាយផ្ទាល់ខ្លួន ដោយចរចារជាមួយឪពុកម្តាយបង្កើតរបស់កូនសុំនោះ ដែលពុំបានប្រព្រឹត្តទៅស្របតាមនីតិវិធីច្បាប់ដែលបានកំណត់ឡើយ។ បានន័យថា ពួកគាត់ខ្វះខាតនូវការយល់ដឹងពីនីតិវិធីច្បាប់ទាក់ទងនឹងការប្រព្រឹត្តទៅនៃសុំកូននេះ។

បន្ថែមលើសពីនេះ រាជរដ្ឋាភិបាលត្រូវមានចំណាត់ការខ្ពស់ ដោយត្រូវចាត់ទុកការសុំកូននេះជាគោលនយោបាយមួយក្នុងគោលដៅមនុស្សធម៌ ដោយផ្សារភ្ជាប់ការគោរព ការអនុវត្តសិទ្ធិ និងឧត្តមប្រយោជន៍របស់កុមារ និង ទប់ស្កាត់រាល់បញ្ហាដែលកើតឡើងតាមរយៈការសុំកូននេះ។ ពិសេស គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ គួររៀបចំសិក្ខាសាលាឲ្យបានច្រើនក្នុងគោលបំណងដើម្បីចែករំលែកពត៌មានទាក់ទងនឹងនីតិវិធីសុំកូននេះ។ មួយវិញទៀត យើងត្រូវដឹងថា កុមារ និងទារកកំព្រាមិនអាចរស់នៅបានដោយសុខស្រួលទេ ប្រសិនបើមិនមានការថែទាំពីគ្រួសារ ប៉ុន្តែក្នុងករណី ដែលមិនមែនគ្រួសារថែទាំពួកគេទេ សាច់ញាតិបន្ទាប់ គឺជាអ្នកមើលថែ ហើយប្រសិនបើមិនមានទៀត គឺនឹងមានការដាក់ឲ្យសុំកូនតែម្តង។

ទោះបីបញ្ញត្តិត្រូវបានពង្រឹង ការគោរពនូវសីលធម៌រស់នៅ និង ភាពថ្លៃថ្នូរជាមនុស្សក៏ចាំបាច់ផនាចំពោះអាណាព្យាបាលគ្រប់រូបទៅលើបញ្ហាសុំកូន។ ការសុំកូន គឺតែងតែមានបញ្ហាចោទកើតឡើងជារឿយៗ ដោយពួកគាត់ ពុំសូវយល់ច្បាស់ពីនីតិវិធីនៃការសុំកូននេះ។ ដូចនេះ ច្បាប់បានកំណត់យ៉ាងច្បាស់ពីការសុំកូន គឺត្រូវធ្វើឡើងដើម្បីលើកស្ទួយឧត្តមប្រយោជន៍របស់កុមារ។ រាល់កុមារ និង កុមារកំព្រាដែលត្រូវការនូវកិច្ចការពារជាពិសេសនោះ សុទ្ធសឹងតែជាកម្មវត្ថុចំបងមួយក្នុងការអភិវឌ្ឍន៍ធនធានមនុស្សសំរាប់ការ បំរើប្រទេសជាតិ។

## ឯកសារយោង

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧
- សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៩
- ក្រមព្រហ្មទណ្ឌនៃព្រះរាជាចក្រកម្ពុជា ឆ្នាំ២០០៩
- សេចក្តីពន្យល់អំពីសុំកូនក្នុងប្រទេស ឆ្នាំ២០១៦
- ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ១៩៨៨
- ច្បាប់ស្តីពីការបង្ក្រាបការជួញដូរ និងអំពើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨
- វចនានុក្រមសម្តេចព្រះសង្ឃរាជ **ជួន ណាត**
- គេហទំព័ររបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

  (www. mosvy.gov.kh)

- https://vannarachincom.wordpress.com/

**មាត្រា ១០០៦.-** អានុភាពប្រតិសកម្មនៃការបញ្ជាក់អំពីអត្ថិភាពនៃមាតុភាព

ការបញ្ជាក់អំពីអត្ថិភាពនៃមាតុភាពត្រូវមានអានុភាពប្រតិសកម្ម តាំងពីពេលកំណើតរបស់កូននោះ ។ ប៉ុន្តែ អានុភាពប្រតិសកម្មនោះ ពុំអាចបំពានសិទ្ធិដែលតតិយជនបានលទ្ធកម្មរួចហើយឡើយ ។

## ផ្នែកទី ២
## សុំកូន

### កថាភាគទី ១
### សុំកូនពេញលេញ

**មាត្រា ១០០៧.-** ទម្រង់នៃការបង្កើតសុំកូនពេញលេញ

បើយល់ឃើញថា មានល័ក្ខខ័ណ្ឌដែលបានកំណត់នៅក្នុងបញ្ញត្តិចាប់ពីមាត្រា ១០០៨ (សុំកូនដោយសហការរវាងប្តីប្រពន្ធ) ដល់មាត្រា ១០១២ (មូលដ្ឋានវិនិច្ឆ័យនៃការបង្កើតសុំកូនពេញលេញ) ខាងក្រោមនេះ តុលាការអាចបង្កើតសុំកូនពេញលេញ ដោយបញ្ចប់ញាតិភាពជាមួយនឹងញាតិលោហិតនៃឪពុកម្តាយបង្កើត តាមពាក្យសុំរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមបាន ។

**មាត្រា ១០០៨.-** សុំកូនដោយសហការរវាងប្តីប្រពន្ធ

១-បុគ្គលដែលក្លាយជាឪពុក ឬ ម្តាយចិញ្ចឹម ត្រូវតែជាបុគ្គលដែលមានសហព័ទ្ធ ។

២-ប្តី ឬ ប្រពន្ធតែម្ខាង ពុំអាចក្លាយជាឪពុក ឬ ម្តាយចិញ្ចឹមបានឡើយ ប្រសិនបើសហព័ទ្ធម្ខាងទៀត មិនក្លាយជាម្តាយ ឬ ឪពុកចិញ្ចឹម ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលប្តីប្រពន្ធណាម្ខាង ក្លាយជាឪពុក ឬ ម្តាយចិញ្ចឹម របស់កូនបង្កើតនៃសហព័ទ្ធម្ខាងទៀត ។

**មាត្រា ១០០៩.-** អាយុរបស់ឪពុកម្តាយចិញ្ចឹម

ឪពុកម្តាយចិញ្ចឹម ត្រូវមានអាយុចាប់ពី ២៥ (ម្ភៃប្រាំ)ឆ្នាំ ឡើងទៅ ហើយត្រូវមាន

អាយុច្រើនជាងកូនសុំយ៉ាងតិច ២០ (ម្ភៃ) ឆ្នាំ ។

**មាត្រា ១០១០.-** អាយុរបស់កូនសុំ

ជាគោលការណ៍ កូនសុំត្រូវមានអាយុតិចជាង ៨ (ប្រាំបី) ឆ្នាំ ។

**មាត្រា ១០១១.-** ការយល់ព្រមរបស់ឪពុកម្ដាយ

ដើម្បីបង្កើតសុំកូនពេញលេញ ត្រូវមានការយល់ព្រមពីឪពុកម្ដាយបង្កើត ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន របស់កុមារដែលនឹងក្លាយជាកូនសុំនោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលឪពុកម្ដាយនោះ មិនអាចបង្ហាញឆន្ទៈបាន ឬ ករណីដែលមានការធ្វើបាបដោយឪពុកម្ដាយ ការបោះបង់កូនចោលដោយគំនិតទុច្ចរិត ឬ ហេតុផ្សេងៗទៀត ដែលបំពានផលប្រយោជន៍របស់កុមារដែលនឹងក្លាយជាកូនសុំនោះ យ៉ាងធ្ងន់ធ្ងរ ។

**មាត្រា ១០១២.-** មូលដ្ឋានវិនិច្ឆ័យនៃការបង្កើតសុំកូនពេញលេញ

សុំកូនពេញលេញ ត្រូវបានបង្កើតឡើង នៅក្នុងករណីដែលមានការពិបាកយ៉ាងខ្លាំង ឬ មិនសមរម្យ ក្នុងការគ្រប់គ្រងថែរក្សាកុមារដែលនឹងក្លាយជាកូនសុំ ដោយឪពុកម្ដាយបង្កើត ឬ មានស្ថានភាពពិសេសផ្សេងៗទៀត បើយល់ឃើញថា មានភាពចាំបាច់ពិសេស ដើម្បីផលប្រយោជន៍របស់កូននោះ ។

**មាត្រា ១០១៣.-** អំឡុងពេលសាកល្បងចិញ្ចឹម

ដើម្បីបង្កើតសុំកូនពេញលេញ តុលាការត្រូវពិចារណាលើស្ថានភាពដែលបុគ្គលដែលនឹងក្លាយជាឪពុកម្ដាយចិញ្ចឹម បានធ្វើ ក្នុងការគ្រប់គ្រងថែរក្សាកុមារដែលនឹងក្លាយជាកូនសុំ ជាគោលការណ៍ យ៉ាងតិច ៦ (ប្រាំមួយ) ខែ ។

**មាត្រា ១០១៤.-** ការបញ្ចប់នូវញាតិភាពជាមួយនឹងឪពុកម្ដាយបង្កើត

ញាតិភាពរវាងកូនសុំ និង ឪពុកម្ដាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុកម្ដាយបង្កើតនោះ ត្រូវបញ្ចប់ ដោយសុំកូនពេញលេញ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមក

អនុវត្តឡើយ ចំពោះញាតិភាពជាមួយនឹងឪពុកម្តាយម្ខាងទៀត និង ញាតិលោហិតរបស់ឪពុកម្តាយម្ខាងទៀតនោះ ដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ២ កថាខណ្ឌទី ២ នៃមាត្រា ១០០៨ (សុំកូនដោយសហការរវាងប្តីប្រពន្ធ) នៃក្រមនេះ ។

**មាត្រា ១០១៥.–** អានុភាពនៃសុំកូនពេញលេញ

១-ដោយបង្កើតសុំកូនពេញលេញ កូនសុំត្រូវទទួលបាននូវឋានៈដូចគ្នានឹងកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹម និង ត្រូវទទួលបាននូវសិទ្ធិ និងករណីយកិច្ច ដូចគ្នានឹងកូនបង្កើតនៅក្នុងទំនាក់ទំនងជាមួយនឹងឪពុកម្តាយចិញ្ចឹម ។

២-កូនសុំ អាចប្រើនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹម ឬ នាមត្រកូលមុនសុំកូនបាន ។

៣-កូនសុំ ត្រូវស្ថិតនៅក្រោមអំណាចមេបារបស់ឪពុកម្តាយចិញ្ចឹម ។ ប៉ុន្តែ ក្នុងករណីដែលប្តីប្រពន្ធណាម្ខាង ក្លាយជាឪពុកចិញ្ចឹម ឬ ម្តាយចិញ្ចឹម របស់កូនបង្កើតរបស់សហព័ទ្ធម្ខាងទៀត កូនសុំនោះត្រូវស្ថិតនៅក្រោមអំណាចមេបារួមរបស់ឪពុកបង្កើត ឬ ម្តាយបង្កើត និង ឪពុកចិញ្ចឹម ឬ ម្តាយចិញ្ចឹម ។

**មាត្រា ១០១៦.–** ការកាត់កាល់នៃសុំកូនពេញលេញ

១-បើយល់ឃើញថាមានភាពចាំបាច់ពិសេសដើម្បីផលប្រយោជន៍របស់កូនសុំ តុលាការអាចកាត់កាល់ភាគីនៃសុំកូនបាន តាមពាក្យសុំរបស់កូនសុំ ឪពុកម្តាយបង្កើត ឬ តំណាងអយ្យការ លុះត្រាតែក្នុងករណីដែលត្រូវនឹងចំណុចទាំងអស់ ដែលកំណត់នៅក្នុងចំណុចនីមួយៗខាងក្រោមនេះ :

ក-បើមានការធ្វើបាបដោយឪពុកម្តាយចិញ្ចឹម បោះបង់កូនសុំចោលដោយគំនិតទុច្ចរិត ឬ ហេតុផ្សេងៗទៀតដែលបំពានផលប្រយោជន៍របស់កូនសុំយ៉ាងធ្ងន់ធ្ងរ ។

ខ-បើឪពុកម្តាយបង្កើតអាចគ្រប់គ្រងថែរក្សាដោយសមរម្យ ។

២-ការកាត់កាល់ ពុំអាចធ្វើបានឡើយ ក្រៅពីយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ១០១៧.–** អានុភាពនៃការកាត់កាល់សុំកូនពេញលេញ

ញាតិភាពរវាងកូនសុំ និង ឪពុកម្តាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយបង្កើតនោះ ដែលត្រូវបានបញ្ចប់ ដោយសុំកូនពេញលេញ ត្រូវកើតឡើងវិញ គិតចាប់ពីថ្ងៃកាត់កាល់ ។

**មាត្រា ១០១៨.–** ការចុះបញ្ជី និង ការរក្សាការសម្ងាត់នៃសុំកូនពេញលេញ

ប្រសិនបើបានបង្កើតសុំកូនពេញលេញ បញ្ជីកំណើតរបស់កូនសុំ ត្រូវធ្វើជាថ្មី ។ ប៉ុន្តែ នៅក្នុងសំបុត្រកំណើត ឬ សេចក្តីចម្លងសំបុត្រកំណើត ឬ ឯកសារដកស្រង់នៃបញ្ជីកំណើត មិនត្រូវសរសេរចំណុចស្តីពីសុំកូនឡើយ ។

**មាត្រា ១០១៩.–** សិទ្ធិដឹងអំពីកំណើតខ្លួន របស់កូនសុំពេញលេញ

កូនសុំពេញលេញ ដែលបានក្លាយជានីតិជន អាចទាមទារឱ្យបង្ហាញនូវព័ត៌មានក្នុងទំហំដែលចាំបាច់ ចំពោះតុលាការដែលរក្សាទុកនូវសំណុំរឿងស្តីពីសុំកូនបាន ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានគោលបំណងមិនត្រឹមត្រូវ ។ ចំពោះការរក្សាទុកសំណុំរឿង និង វិធីទាមទារឱ្យបង្ហាញ ជាអាទិ៍ ត្រូវកំណត់នៅក្នុងបទ-ប្បញ្ញត្តិរបស់តុលាការ ។

## កថាភាគទី ២

## សុំកូនធម្មតា

**មាត្រា ១០២០.–** ពាក្យសុំនៃសុំកូនធម្មតា

១-បុគ្គលដែលមានអាយុចាប់ពី ២៥ (ម្ភៃប្រាំ) ឆ្នាំ ឡើងទៅ អាចដាក់ពាក្យសុំជាមួយនឹងបុគ្គលដែលនឹងក្លាយជាកូនសុំ ទៅតុលាការ ឱ្យបង្កើតសុំកូនធម្មតាបាន ។ ប៉ុន្តែ បុគ្គលដែលនឹងក្លាយជាកូនសុំ មិនត្រូវជាបុព្វញាតិរបស់បុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម ឬ បុគ្គលដែលមានអាយុច្រើនជាងបុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹមឡើយ ។

២-ក្នុងករណីដែលបុគ្គលដែលនឹងក្លាយជាកូនសុំ ជាអនីតិជន អ្នកមានអំណាច

មេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ត្រូវដាក់ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ក្នុងនាមជាអ្នកតំណាងដែលច្បាប់បានកំណត់ ។

**មាត្រា ១០២១.-** ករណីដែលបុគ្គលដែលនឹងក្លាយជាឪពុកឬម្ដាយចិញ្ចឹមមានសហព័ទ្ធ

បើបុគ្គលដែលមានសហព័ទ្ធ សុំកូនដែលជាអនីតិជន បុគ្គលនោះត្រូវដាក់ពាក្យសុំដែលបានកំណត់នៅក្នុងមាត្រា ១០២០ (ពាក្យសុំនៃសុំកូនធម្មតា) ខាងលើនេះ ជាមួយនឹងសហព័ទ្ធរបស់ខ្លួន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលយកកូនរបស់សហព័ទ្ធ មកធ្វើជាកូនសុំ ឬ ករណីដែលសហព័ទ្ធមិនអាចបង្ហាញឆន្ទៈរបស់ខ្លួនបាន ។

**មាត្រា ១០២២.-** ការយល់ព្រមរបស់សហព័ទ្ធ

ចំពោះបុគ្គលដែលមានសហព័ទ្ធ ដើម្បីដាក់ពាក្យសុំនៃសុំកូនធម្មតា ត្រូវទទួលការយល់ព្រមពីសហព័ទ្ធរបស់ខ្លួន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលដាក់ពាក្យសុំដែលបានកំណត់នៅក្នុងមាត្រា ១០២០ (ពាក្យសុំនៃសុំកូនធម្មតា) ខាងលើនេះ ជាមួយនឹងសហព័ទ្ធ ឬ ករណីដែលសហព័ទ្ធមិនអាចបង្ហាញឆន្ទៈរបស់ខ្លួនបាន ។

**មាត្រា ១០២៣.-** មូលដ្ឋានវិនិច្ឆ័យនៃការបង្កើតសុំកូនធម្មតា

១-តុលាការ អាចឱ្យបង្កើតសុំកូនបាន លុះត្រាតែករណីដែលអាចបញ្ជាក់អំពីឆន្ទៈពិតប្រាកដរបស់ភាគី ក្នុងការបង្កើតទំនាក់ទំនងរវាងឪពុកម្ដាយ និង កូន ។

២-តុលាការមិនត្រូវឱ្យបង្កើតសុំកូនឡើយ បើយល់ឃើញថា សុំកូនត្រូវបានបំពានក្នុងគោលបំណងរៀបអាពាហ៍ពិពាហ៍ រវាងភេទផ្សេងគ្នា ឬ ភេទដូចគ្នា ឬ ក្នុងគោលបំណងមិនត្រឹមត្រូវផ្សេងទៀត ។

**មាត្រា ១០២៤.-** ករណីដែលបុគ្គលដែលនឹងក្លាយជាកូនសុំ ជាអនីតិជន

១-បើបុគ្គលដែលនឹងក្លាយជាកូនសុំ ជាអនីតិជន តុលាការអាចឱ្យបង្កើតសុំកូនបាន លុះត្រាតែយល់ឃើញថា មានភាពចាំបាច់ពិសេសដើម្បីផលប្រយោជន៍របស់អនីតិជន

នោះ ។

២-ក្នុងករណីដែលបុគ្គលដែលនឹងក្លាយជាកូនសុំ ជាអនីតិជន បើឪពុកម្ដាយបង្កើតរបស់បុគ្គលនោះបានលែងលះហើយ តុលាការត្រូវសួរយោបល់របស់ឪពុក ឬ ម្ដាយដែលមិនមែនជាអ្នកមានអំណាចមេបា ដើម្បីវិនិច្ឆ័យអំពីចំណុចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

៣-បើអនីតិជនបានដល់អាយុ ១៥ (ដប់ប្រាំ) ឆ្នាំ ដើម្បីបង្កើតសុំកូន ត្រូវទទួលការយល់ព្រមពីអនីតិជននោះ ។ ទោះបីជាអនីតិជននោះមិនទាន់ដល់អាយុ ១៥ (ដប់ប្រាំ) ឆ្នាំក៏ដោយ បើអនីតិជននោះអាចបង្ហាញឆន្ទៈរបស់ខ្លួនបាន តុលាការត្រូវសួរយោបល់របស់អនីតិជននោះ ដើម្បីវិនិច្ឆ័យអំពីចំណុចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ១០២៥.-** សុំកូន រវាងអ្នកអាណាព្យាបាល និង ជននៅក្រោមអាណាព្យាបាល

ក្នុងករណីដែលអ្នកអាណាព្យាបាលសម្រាប់អនីតិជន ដាក់ពាក្យសុំឱ្យបង្កើតសុំកូនដោយយកអនីតិជននៅក្រោមអាណាព្យាបាលរបស់ខ្លួន មកធ្វើជាកូនសុំ ឬ ក្នុងករណីដែលអ្នកអាណាព្យាបាលទូទៅ ដាក់ពាក្យសុំឱ្យបង្កើតសុំកូន ដោយយកជននៅក្រោមអាណាព្យាបាលទូទៅរបស់ខ្លួន មកធ្វើជាកូនសុំ តុលាការអាចឱ្យបង្កើតសុំកូនបាន លុះត្រាតែក្នុងករណីដែលបានអនុវត្តត្រឹមត្រូវ ក្នុងការគ្រប់គ្រងថែរក្សាជននៅក្រោមអាណាព្យាបាល និង ការគ្រប់គ្រងទ្រព្យសម្បត្តិ ។ បញ្ញត្តិនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលតួនាទីរបស់អ្នកអាណាព្យាបាលបានចប់ តែមិនទាន់បានបញ្ចប់ការគណនានូវចំណូលចំណាយក្នុងការគ្រប់គ្រង ។

**មាត្រា ១០២៦.-** អានុភាពនៃសុំកូនធម្មតា ចំពោះបុគ្គភាព

១-ទោះបីជាមានការបង្កើតសុំកូនធម្មតាក៏ដោយ ញាតិភាពរវាងកូនសុំ និង ឪពុកម្ដាយបង្កើត ត្រូវបន្តអត្ថិភាព ហើយកូនសុំ និង ឪពុកម្ដាយបង្កើត មានសិទ្ធិធ្វើសន្តតិកម្មគ្នាទៅវិញទៅមក ។

២-កូនសុំ និង ឪពុកម្ដាយបង្កើត មានសិទ្ធិទាមទារ និង ករណីយកិច្ចផ្គត់ផ្គង់

អាហារកាតព្វកិច្ច ។

**មាត្រា ១០២៧.–** អានុភាពនៃសុំកូន ក្នុងទំនាក់ទំនងជាមួយនឹងឪពុកម្តាយចិញ្ចឹម ជាអាទិ៍

១-បញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ១០១៥ (អានុភាពនៃសុំកូនពេញលេញ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសុំកូនធម្មតា ។

២-កូនសុំ អាចប្រើនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹម ឬ នាមត្រកូលមុនសុំកូនបាន ។

៣-ក្នុងករណីដែលកូនសុំ ជាអនីតិជន កូនសុំត្រូវស្ថិតនៅក្រោមអំណាចមេបារបស់ឪពុកម្តាយចិញ្ចឹម ឪពុកចិញ្ចឹម ឬ ម្តាយចិញ្ចឹម ។ ប៉ុន្តែ ក្នុងករណីដែលយកកូនបង្កើតរបស់សហព័ទ្ធ មកធ្វើជាកូនសុំ កូនសុំនោះត្រូវស្ថិតនៅក្រោមអំណាចមេបារួមរបស់ឪពុក ឬ ម្តាយចិញ្ចឹម និង សហព័ទ្ធនោះ ។

**មាត្រា ១០២៨.–** ពាក្យសុំឱ្យកាត់កាល់សុំកូនធម្មតា

១-ភាគីនៃសុំកូន អាចដាក់ពាក្យសុំទៅតុលាការ ឱ្យកាត់កាល់សុំកូនបាន ក្នុងករណីដែលភាគីសងខាងព្រមព្រៀងអំពីការកាត់កាល់នោះ ។

២-ក្នុងករណីដែលកូនសុំជាអនីតិជន ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើឡើង ដោយឪពុកម្តាយចិញ្ចឹម និង បុគ្គលដែលត្រូវក្លាយជាអ្នកតំណាងដែលច្បាប់បានកំណត់ ក្រោយពេលកាត់កាល់ ។ ប៉ុន្តែ បើកូនសុំដល់អាយុ ១៥ (ដប់ប្រាំ) ឆ្នាំ ហើយ ត្រូវទទួលការយល់ព្រមពីកូនសុំនោះ ។ ទោះបីជាអនីតិជននោះមិនទាន់ដល់អាយុ ១៥ (ដប់ប្រាំ) ឆ្នាំ ក៏ដោយ បើអនីតិជននោះអាចបង្ហាញឆន្ទៈរបស់ខ្លួនបាន តុលាការត្រូវសួរយោបល់របស់អនីតិជននោះ ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ បើឪពុកម្តាយបង្កើតរបស់កូនសុំ បានលែងលះគ្នាហើយ ឪពុកម្តាយបង្កើតរបស់កូនសុំនោះ ត្រូវពិភាក្សា និង កំណត់ថា ឪពុក ឬ ម្តាយបង្កើត ជាបុគ្គលដែលត្រូវក្លាយជាអ្នកមានអំណាចមេបា នៅក្រោយពេលកាត់កាល់ ។

៤-បើការពិភាក្សាដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ពុំបានសម្រេច ឬ បើពុំអាចពិភាក្សាបានទេ តុលាការត្រូវកំណត់បុគ្គលដែលត្រូវក្លាយជាអ្នកមានអំណាចមេបា ដោយគិតពិចារណាទៅលើផលប្រយោជន៍របស់កូន ។

**មាត្រា ១០២៩.-** ការកាត់កាល់រវាងប្ដីប្រពន្ធដែលបានសុំកូនដោយសហការ និង កូនសុំជាអនីតិជន

ក្នុងករណីដែលប្ដីប្រពន្ធដែលបានសុំកូនដោយសហការគ្នា ជាឪពុកម្ដាយចិញ្ចឹម ដើម្បីកាត់កាល់កូនសុំជាអនីតិជន ប្ដីប្រពន្ធត្រូវដាក់ពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១០២៨ (ពាក្យសុំឱ្យកាត់កាល់ស៊ុំកូនធម្មតា) ខាងលើនេះ ជាមួយគ្នា ។ ប៉ុន្តែបញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះប្ដីប្រពន្ធណាម្ខាងមិនអាចបង្ហាញឆន្ទៈរបស់ខ្លួន ។

**មាត្រា ១០៣០.-** ការវិនិច្ឆ័យអំពីការកាត់កាល់ស៊ុំកូនធម្មតា

បើមានពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១០២៨ (ពាក្យសុំឱ្យកាត់កាល់ស៊ុំកូនធម្មតា) ខាងលើនេះ តុលាការអាចសម្រេចឱ្យកាត់កាល់ស៊ុំកូនបាន លុះត្រាតែបានបញ្ជាក់ថា ភាគីសងខាងមានបំណងពិតប្រាកដ ក្នុងការរំលាយទំនាក់ទំនងរវាងឪពុកម្ដាយ និង កូន ។

**មាត្រា ១០៣១.-** មូលហេតុនៃការកាត់កាល់

១-ភាគីម្ខាងនៃស៊ុំកូន អាចដាក់ពាក្យបណ្ដឹងទាមទារឱ្យកាត់កាល់បាន លុះត្រាតែក្នុងករណីខាងក្រោមនេះ :

ក-បើត្រូវបានបោះបង់ចោល ដោយភាគីម្ខាងទៀត ដោយទុច្ចរិត ។

ខ-បើមិនច្បាស់ ក្នុងអំឡុងពេលយ៉ាងតិច ១ (មួយ) ឆ្នាំ ថាភាគីម្ខាងទៀតនៅរស់ ឬ ទទួលមរណភាព ។

គ-បើមានហេតុធ្ងន់ធ្ងរផ្សេងទៀត ដែលបណ្ដាលឱ្យមានការពិបាកក្នុងការបន្តស៊ុំកូន ។

២-ក្នុងអំឡុងពេលដែលកូនសុំពុំទាន់ក្លាយជានីតិជន ឪពុកម្ដាយចិញ្ចឹម មិនអាចដាក់ពាក្យបណ្ដឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំពោះកូនសុំបានឡើយ ។

៣-បើកូនសុំជាអនីតិជន បញ្ញត្តិចាប់ពីកថាខណ្ឌទី ២ ដល់កថាខណ្ឌទី ៤ នៃមាត្រា ១០២៨ (ពាក្យសុំឱ្យកាត់កាល់សុំកូនធម្មតា) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលកូនសុំដាក់ពាក្យបណ្ដឹងដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំពោះឪពុកម្ដាយចិញ្ចឹម ។

**មាត្រា ១០៣២.-** អានុភាពនៃការកាត់កាល់សុំកូនធម្មតា

១-អានុភាពទាំងឡាយនៃសុំកូនធម្មតា ត្រូវបញ្ចប់ឆ្ពោះទៅអនាគត ដោយការកាត់កាល់ ។

២-ក្រោយការកាត់កាល់ កូនសុំអាចទទួលវិញ នូវនាមត្រកូលមុនសុំកូនក៏បាន ឬអាចប្រើនាមត្រកូលរបស់ឪពុកម្ដាយចិញ្ចឹមក៏បាន ។

**មាត្រា ១០៣៣.-** ការចុះបញ្ជីនៃសុំកូនធម្មតា និង បញ្ជីកំណើត

ប្រសិនបើបានបង្កើតសុំកូនធម្មតា ត្រូវសរសេរការបង្កើតសុំកូនធម្មតា នៅលើរឹមទំព័រនៃបញ្ជីកំណើតដើមរបស់កូនសុំនោះ ។

## ជំពូកទី ៥
## អំណាចមេបា

### ផ្នែកទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ១០៣៤.-** អត្ថន័យនៃអំណាចមេបា

អ្នកដែលមានអំណាចមេបា មានសិទ្ធិ និង ករណីយកិច្ច ត្រូវថែបាច់រក្សារូបកាយ

របស់កូនដែលជាអនីតិជន និង គ្រប់គ្រងទ្រព្យសម្បត្តិរបស់កូននោះ ។

**មាត្រា ១០៣៥.–** អំណាចមេបាលើកូនសុំ

អ្នកដែលមានអំណាចមេបាលើកូនសុំ គឺឪពុកម្ដាយចិញ្ចឹម ។

**មាត្រា ១០៣៦.–** គោលការណ៍នៃការសហការប្រើប្រាស់អំណាចមេបា

ឪពុកម្ដាយដែលមានចំណងអាពាហ៍ពិពាហ៍ ត្រូវប្រើប្រាស់អំណាចមេបាដោយសហការគ្នា ។ ប៉ុន្តែ បើឪពុក ឬ ម្ដាយណាម្ខាង ពុំអាចប្រើប្រាស់អំណាចមេបាបានទេ ឪពុក ឬ ម្ដាយម្ខាងទៀតត្រូវប្រើអំណាចមេបានោះ ។

## ផ្នែកទី ២

## ការសម្រេចអំពីអ្នកមានអំណាចមេបា ក្នុងករណីលែងលះគ្នា និង ការទទួលស្គាល់

**មាត្រា ១០៣៧.–** ការសម្រេចអំពីអ្នកមានអំណាចមេបា នៅពេលលែងលះគ្នា

១-បើឪពុកម្ដាយលែងលះគ្នា ត្រូវកំណត់យកឪពុក ឬ ម្ដាយណាម្ខាង ជាអ្នកមានអំណាចមេបា តាមការពិភាក្សារបស់ឪពុកម្ដាយ ។

២-ក្នុងករណីដែលឪពុកម្ដាយបានលែងលះគ្នានៅមុនកំណើតរបស់កូន ម្ដាយគឺជាអ្នកមានអំណាចមេបាចំពោះកូនដែលបានកើតមកនោះ ។ ប៉ុន្តែ នៅក្រោយកំណើតរបស់កូន អាចកំណត់យកឪពុកជាអ្នកមានអំណាចមេបា តាមការពិភាក្សារបស់ឪពុកម្ដាយបាន ។

៣-បើការពិភាក្សានៃកថាខណ្ឌទី ១ ឬ កថាខណ្ឌទី ២ ខាងលើនេះ ពុំបានសម្រេច ឬ បើពុំអាចពិភាក្សាបានទេ តុលាការត្រូវកំណត់អ្នកមានអំណាចមេបា ដោយពិចារណាទៅលើផលប្រយោជន៍របស់កូននោះ ។

**មាត្រា ១០៣៨.–** ទំនាក់ទំនងរវាងការទទួលស្គាល់ និង អំណាចមេបា

១-អ្នកមានអំណាចមេបាលើកូន ដែលម្ដាយមិនទាន់បានរៀបអាពាហ៍ពិពាហ៍បានបង្កើត គឺម្ដាយ ។

២-ឪពុក អាចប្រើប្រាស់អំណាចមេបា ចំពោះកូនដែលខ្លួនបានទទួលស្គាល់បាន

តែក្នុងករណីដែលការពិភាក្សារបស់ឪពុកម្ដាយ បានកំណត់យកឪពុកនោះ ជាអ្នកមានអំណាចមេបា ។

៣-បើការពិភាក្សាដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ពុំបានសម្រេច ឬ បើពុំអាចធ្វើការពិភាក្សានោះបានទេ តុលាការត្រូវកំណត់អ្នកមានអំណាចមេបា តាមការទាមទាររបស់ឪពុក ឬ ម្ដាយ ។

៤-ក្រោយពេលដែលឪពុកបានទទួលស្គាល់កូនហើយ ប្រសិនបើឪពុកម្ដាយបានរៀបអាពាហ៍ពិពាហ៍ ឪពុកម្ដាយត្រូវអនុវត្តអំណាចមេបា ដោយសហការគ្នា ។

**មាត្រា ១០៣៩.–** ការផ្លាស់ប្ដូរអ្នកដែលមានអំណាចមេបា

នៅក្នុងករណីនៃបញ្ញត្តិមាត្រា ១០៣៧ (ការសម្រេចអំពីអ្នកមានអំណាចមេបា នៅពេលលែងលះគ្នា) និង មាត្រា ១០៣៨ (ទំនាក់ទំនងរវាងការទទួលស្គាល់ និង អំណាចមេបា) ខាងលើនេះ តុលាការអាចផ្លាស់ប្ដូរអ្នកដែលមានអំណាចមេបា តាមការទាមទាររបស់ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់កូនបាន ប្រសិនបើទទួលស្គាល់ថាចាំបាច់ដើម្បីផលប្រយោជន៍របស់កូន ។

**មាត្រា ១០៤០.–** សិទ្ធិ និង ករណីយកិច្ចរបស់ឪពុកម្ដាយដែលមិនរស់នៅជាមួយកូន

១-ឪពុក ឬ ម្ដាយ ដែលពុំមានអំណាចមេបា ក្រោយពេលលែងលះគ្នា មានសិទ្ធិចូលជួប និង ប្រាស្រ័យទាក់ទងជាមួយកូន និង មានករណីយកិច្ចទទួលបន្ទុកលើសោហ៊ុយដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន ។

២-ឪពុកម្ដាយដែលមានបំណងចង់លែងលះគ្នា ត្រូវពិភាក្សា និង កំណត់អំពីរបៀបចូលជួប និង ប្រាស្រ័យទាក់ទងជាមួយកូន និង សោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូន ។

៣-ឪពុកដែលមិនបានរស់នៅជាមួយកូនដែលបានទទួលស្គាល់ អាចពិភាក្សា និង កំណត់ ជាមួយម្ដាយ អំពីរបៀបចូលជួប ប្រាស្រ័យទាក់ទង និង សោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូនបាន ។

៤-បើការពិភាក្សាដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ និង ទី ៣ ខាងលើនេះ

ពុំបានសម្រេច ឬ បើពុំអាចធ្វើការពិភាក្សាបានទេ តុលាការត្រូវកំណត់អំពីរបៀបចូលជួប ប្រាស្រ័យទាក់ទង និង សោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូន តាមការទាមទាររបស់ឪពុក ឬ ម្ដាយ ។

៥-បើទទួលស្គាល់ថាចាំបាច់ដើម្បីផលប្រយោជន៍របស់កូន តុលាការអាចផ្លាស់ប្ដូររបៀបចូលជួប ប្រាស្រ័យទាក់ទង និង សោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូន តាមការទាមទាររបស់ឪពុក ឬ ម្ដាយ បាន ។

៦-នៅក្នុងការសម្រេចសេចក្ដីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៤ និង ទី ៥ ខាងលើនេះ តុលាការត្រូវកំណត់អំពីការចូលជួប ប្រាស្រ័យទាក់ទង ដោយយកផលប្រយោជន៍របស់កូនជាអាទិភាព និង ត្រូវកំណត់អំពីសោហ៊ុយចាំបាច់ដែលត្រូវទទួលបន្ទុកដើម្បីគ្រប់គ្រងថែរក្សាកូន ដោយគិតពិចារណាទៅលើស្ថានភាពនៃជីវភាព និង ស្ថានភាពសេដ្ឋកិច្ចរបស់ឪពុកម្ដាយ ។

៧-ប្រសិនបើឪពុក ឬ ម្ដាយ មិនអាចពិភាក្សា ឬ មិនអាចទាមទារទៅតុលាការបានទេ ញាតិនៅក្នុង ៤ (បួន) ថ្នាក់ របស់កូន អាចធ្វើការទាមទារដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៤ និង ទី ៥ ខាងលើនេះបាន ។

**មាត្រា ១០៤១.-** សិទ្ធិទាមទារឱ្យរាយការណ៍អំពីស្ថានភាពរបស់កូន

១-ឪពុក ឬ ម្ដាយ ដែលពុំមានអំណាចមេបាលើកូន អាចទាមទារឱ្យអ្នកដែលមានអំណាចមេបា រាយការណ៍អំពីស្ថានភាពរបស់កូននោះបាន ។

២-ចំពោះខ្លឹមសារ និង របៀបរបបនៃការរាយការណ៍ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវកំណត់តាមការពិភាក្សារវាងឪពុកម្ដាយ ។ ប៉ុន្តែ បើការពិភាក្សាពុំបានសម្រេច ឬ បើពុំអាចធ្វើការពិភាក្សាបានទេ តុលាការអាចសម្រេចសេចក្ដីជំនួសការពិភាក្សា តាមការទាមទាររបស់ឪពុក ឬ ម្ដាយ បាន ។

៣-ញាតិក្នុង ៤ (បួន) ថ្នាក់ របស់កូន អាចទាមទារឱ្យរាយការណ៍អំពីស្ថានភាពរបស់កូនចំពោះអ្នកមានអំណាចមេបាបាន ។

**មាត្រា ១០៤២.–** ករណីយកិច្ចពិភាក្សាអំពីចំណុចសំខាន់ៗទាក់ទងទៅនឹងកូន

លើកលែងតែករណីដែលមានភាពចាំបាច់បន្ទាន់ អ្នកដែលមានអំណាចមេបា ត្រូវពិភាក្សាជាមួយឪពុក ឬ ម្ដាយ ដែលពុំមានអំណាចមេបា អំពីចំណុចដែលទាក់ទងទៅនឹងកូន ដូចមានកំណត់ខាងក្រោមនេះ ៈ

ក-ការអប់រំរបស់កូន ដែលហួសពីកម្រិតនៃកាតព្វកិច្ចអប់រំដែលជាករណីយកិច្ចកំណត់ដោយច្បាប់ ។

ខ-ការផ្លាស់ប្ដូរទីសំណាក់របស់កូន ពីខេត្ត-ក្រុងមួយ ទៅខេត្ត-ក្រុងមួយទៀត ។

គ-វិជ្ជាជីវៈ ឬ អាជីវកម្មរបស់កូន ។

ឃ-សកម្មភាពព្យាបាល ដែលទាក់ទងដល់អាយុជីវិតរបស់កូន ។

ង-ការចាត់ចែងទ្រព្យសម្បត្តិសំខាន់របស់កូន ។

ច-ចំណុចសំខាន់ៗផ្សេងទៀត ដែលទាក់ទងទៅនឹងការគ្រប់គ្រងថែរក្សាកូន និង ទ្រព្យសម្បត្តិរបស់កូន ។

## ផ្នែកទី ៣
## សិទ្ធិ និង ករណីយកិច្ចរបស់អ្នកដែលមានអំណាចមេបា

**មាត្រា ១០៤៣.–** ការអប់រំកូន

អ្នកមានអំណាចមេបា មានសិទ្ធិ និង ករណីយកិច្ចអប់រំកូន ។

**មាត្រា ១០៤៤.–** ទីសំណាក់របស់កូន

ទីសំណាក់របស់កូន ត្រូវកំណត់នៅទីកន្លែងដែលអ្នកមានអំណាចមេបា បានកំណត់ ។

**មាត្រា ១០៤៥.–** ការដាក់ទណ្ឌកម្មកូន

អ្នកមានអំណាចមេបា អាចដាក់ទណ្ឌកម្មកូន ដោយខ្លួនឯង នៅក្នុងទំហំដែលចាំបាច់បាន ។

**មាត្រា ១០៤៦.-** ការអនុញ្ញាតឱ្យប្រកបវិជ្ជាជីវៈ និង អាជីវកម្ម

១-កូន មិនអាចប្រកបវិជ្ជាជីវៈបានឡើយ បើមិនបានទទួលការអនុញ្ញាតពីអ្នកមានអំណាចមេបា ។

២-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ២ មាត្រា ២០ (អនីតិជនដែលត្រូវបានអនុញ្ញាតឱ្យប្រកបអាជីវកម្ម) នៃក្រមនេះ អ្នកមានអំណាចមេបា អាចលុបចោល ឬ កម្រិតការអនុញ្ញាត ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើ នេះបាន ។

**មាត្រា ១០៤៧.-** ការទាមទារឱ្យប្រគល់កូន

១-អ្នកមានអំណាចមេបា អាចទាមទារឱ្យតតិយជន ដែលមិនព្រមប្រគល់កូន ដោយផ្ទុយនឹងច្បាប់ ប្រគល់កូនបាន ។

២-អ្នកមានអំណាចមេបា អាចទាមទារឱ្យឪពុក ឬ ម្ដាយ ដែលពុំមានអំណាចមេបា ប្រគល់កូនបាន ។

## ផ្នែកទី ៤
## ការល្បួរ និង ការដកហូតអំណាចមេបា

**មាត្រា ១០៤៨.-** ការប្រកាសការល្បួរ ឬ ការដកហូតអំណាចមេបា

បើឪពុក ឬ ម្ដាយដែលអនុវត្តអំណាចមេបា បានបំពានសិទ្ធិអំណាចក្នុងនាមជាអ្នកមានអំណាចមេបា ឬ បើបានធ្វេសប្រហែសក្នុងការបំពេញករណីយកិច្ចក្នុងនាមជាអ្នកមានអំណាចមេបា តុលាការអាចប្រកាសល្បួរ ឬ ការដកហូតអំណាចមេបា តាមការទាមទាររបស់ញាតិក្នុង ៤ (បួន) ថ្នាក់ របស់កូន មេឃុំ ឬ ចៅសង្កាត់ នាយកមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខុមាលភាពកុមារ ឬ តំណាងអយ្យការបាន ។

**មាត្រា ១០៤៩.-** ការលុបចោលនូវការប្រកាសការល្បួរ ឬ ការដកហូតអំណាចមេបា

បើមូលហេតុដែលបានកំណត់ក្នុងមាត្រា ១០៤៨ (ការប្រកាសការល្បួរ ឬ ការដកហូតអំណាចមេបា) ខាងលើនេះ បានបញ្ចប់ហើយ តុលាការអាចលុបចោលការប្រកាសការ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីពន្យល់
# អំពី
# សុំកូនឆ្លងប្រទេស


បោះពុម្ពផ្សាយលើកទី១
ខែសីហា ឆ្នាំ២០១៦
ចំនួន ៥០០ក្បាល


unicef
unite for children

# ១. គោលបំណងនៃសេចក្តីពន្យល់អំពីសុំកូនក្នុងប្រទេស

សេចក្តីពន្យល់នេះ មានកំណត់ពន្យល់អំពីសុំកូនក្នុងប្រទេស ផ្អែកតាមក្រមរដ្ឋប្បវេណី ច្បាប់ស្តីពី "នីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង" និងលិខិតបទដ្ឋានគតិយុត្តិផ្សេងទៀតដែលពាក់ព័ន្ធ។

សេចក្តីពន្យល់នេះ មានគោលបំណងអោយបុគ្គលដែលពាក់ព័ន្ធនឹងសុំកូន ជាពិសេសចៅក្រម តំណាងអយ្យការ មេធាវី អ្នកគាំទ្រគ្រួសារ ភ្នាក់ងារ ឬ មន្ត្រីសង្គមកិច្ច និងអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀត បានដឹងអំពីគោលការណ៍ លក្ខខណ្ឌ នីតិវិធី ទម្រង់បែបបទនិងអានុភាពនៃសុំកូនក្នុងប្រទេស។

ម្យ៉ាងទៀត សេចក្តីពន្យល់នេះមានគោលដៅ **ធានាឧត្តមប្រយោជន៍ និងការពារសិទ្ធិជា មូលដ្ឋានរបស់កុមារ** ដូចជាកុមារដែលត្រូវការកិច្ចការពារពិសេស ឬ កុមារកំពុងប្រឈមនឹងគ្រោះថ្នាក់ ដើម្បីឱ្យកុមារទាំងនោះមានការអភិវឌ្ឍន៍ពេញលេញ ក្នុងបរិយាកាសគ្រួសារប្រកប ដោយសុភមង្គល សេចក្តីស្រឡាញ់ និងការយោគយល់ ។

ផ្អែកតាមក្រមរដ្ឋប្បវេណី ការសុំកូនរួមមានៈ សុំកូនពេញលេញ និង សុំកូនធម្មតា ។ តែសេចក្តីពន្យល់នេះនឹងធ្វើការពន្យល់ផ្តោតលើសុំកូនពេញលេញជាចម្បង។

# ២. គោលការណ៍នៃសុំកូនក្នុងប្រទេស

យោងតាមគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិ (UN) ចែងថា "សុំកូនក្នុងប្រទេស សំដៅដល់ការថែទាំដែលផ្តល់ទៅឱ្យកុមារដែលមិនស្ថិតនៅក្រោមការថែទាំរបស់ឪពុកម្តាយបង្កើតរបស់ខ្លួន" ។

ក្រៅពីក្រមរដ្ឋប្បវេណី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានចេញប្រកាសស្តីពី **"នីតិវិធីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ"** ដោយមានចែងអំពីគោលការណ៍នៃសុំកូនក្នុងប្រទេសដូចតទៅ :

ពាក្យថា "ដំណោះស្រាយអចិន្ត្រៃយ៍ឱ្យកុមារ" ខាងលើនេះ រួមមានការថែរក្សាកុមារជាអចិន្ត្រៃយ៍ជាមួយសាច់ញាតិ ជាមួយអាណាព្យាបាលក្នុងប្រទេស។ ហើយ ប្រការ២៨នៃប្រកាសខាងលើនេះ ចែងថា សុំកូនក្នុងប្រទេស គឺជាកិច្ចការមានអាទិភាពបំផុត ក្នុងចំណោមដំណោះស្រាយអចិន្ត្រៃយ៍ ឱ្យកុមារដែលមិនស្ថិតនៅក្រោមការថែទាំរបស់ឪពុកម្តាយបង្កើតរបស់ខ្លួន ។

## ៩. សុំកូនក្នុងប្រទេស ត្រូវអនុវត្តតាមគោលការណ៍នៃការធ្វើផែនការអចិន្ត្រៃយ៍ដូចមានចែងនៅក្នុងជំពូកទី ៧ (ការធ្វើផែនការអចិន្ត្រៃយ៍) នៃប្រកាសស្តីពីនីតិវិធីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ។

ពាក្យថា"ផែនការអចិន្ត្រៃយ៍"ខាងលើនេះ សំដៅដល់កិច្ចខិតខំប្រឹងប្រែងរកគ្រួសារមួយឱ្យកុមារដើម្បីរស់នៅជាមួយជាអចិន្ត្រៃយ៍ តាមរយៈការទុកដាក់ជាមួយញាតិ ឬជាមួយអាណាព្យាបាលក្នុងប្រទេស សុំកូនក្នុងប្រទេស និងសុំកូនអន្តរប្រទេស (ប្រការ៥នៃប្រកាស)។ដូច្នេះ សុំកូនក្នុងប្រទេស គឺជាប្រភេទមួយនៃការធ្វើផែនការទុកដាក់កុមារឱ្យរស់នៅជាមួយគ្រួសារជាអចិន្ត្រៃយ៍ ។ ហេតុនេះហើយ សុំកូនក្នុងប្រទេសត្រូវអនុវត្តតាមគោលការណ៍នៃការធ្វើផែនការអចិន្ត្រៃយ៍ដូចមានចែងនៅក្នុងជំពូកទី៧ (ការធ្វើផែនការអចិន្ត្រៃយ៍) នៃប្រកាសខាងលើនេះ។

នៅក្នុងជំពូកទី ៧ នេះ មានប្រការ ២៤ ដែលបញ្ញត្តិថា កុមារដែលបានធ្វើសេវារក្សាក្នុងគ្រួសារបង្កើត (ឧទាហរណ៍ មន្ត្រីសង្គមកិច្ចផ្តល់ការពន្យល់ណែនាំ គាំទ្រទាំងផ្នែកស្មារតី និងសម្ភារៈ ដើម្បីកុំអោយឪពុកម្តាយបង្កើតបោះបង់កូនចោល) និងសេវាបង្រួបបង្រួមគ្រួសារអោយអស់លទ្ធភាព(ឧទាហរណ៍ ក្រោយពីរកឃើញឪពុកម្តាយបង្កើតរបស់កុមារហើយ មន្ត្រីសង្គមកិច្ចត្រូវធ្វើការបង្រួបបង្រួមអោយឪពុកម្តាយ និងកូនយល់ព្រមរស់នៅជាមួយគ្នាវិញ) ហើយត្រូវបញ្ជូនទៅរកសេវាការធ្វើផែនការទុកដាក់កុមារឱ្យរស់នៅជាមួយគ្រួសារជាអចិន្ត្រៃយ៍ (ឧទាហរណ៍: ក្នុងករណីដែលមន្ត្រីសង្គមកិច្ចមិនអាចធ្វើការបង្រួបបង្រួមកុមារអោយរស់នៅជាមួយគ្រួសារដើមវិញទេនោះ មន្ត្រីសង្គមកិច្ចត្រូវរៀបចំរកឪពុកម្តាយចិញ្ចឹមស្របតាមច្បាប់អោយកុមារ) តាមនីតិវិធីដូចខាងក្រោមនេះ :

១- មុនពេលចាប់ផ្តើមធ្វើផែនការអចិន្ត្រៃយ៍ ត្រូវមានឯកសារគ្រប់គ្រាន់ដែលបញ្ជាក់ពីការប្រឹងប្រែងនៃការផ្តល់សេវារក្សាកុមារក្នុងគ្រួសារ និងសេវាបង្រួបបង្រួមគ្រួសារដែលបាន

ដើម្បីបំពេញល័ក្ខខ័ណ្ឌខាងលើនេះ តុលាការត្រូវជឿជាក់ថាសុំកូនពេញលេញនោះនឹងធានាដល់ផលប្រយោជន៍របស់កុមារដោយសង្កត់ធ្ងន់ជាពិសេសថា តាមរយៈសុំកូននេះនឹងផ្តល់ឱ្យកុមារនូវគ្រួសារដែលមានស្ថិរភាពនិងភាពសុខដុមរមនា។ពីព្រោះថា សុំកូនពេញលេញត្រូវឆ្លើយតបដោយផ្ទាល់ទៅនឹងសុខុមាលភាពកុមារ និងឧត្តមប្រយោជន៍របស់កុមារ។

ដូច្នេះ ដើម្បីធានាឧត្តមប្រយោជន៍របស់កុមារខាងលើនេះតុលាការត្រូវគិតពិចារណាព័ត៌មានផ្សេងៗដូចតទៅ (ប្រការ២៨ នៃ**ប្រកាសស្តីពីនីតិវិធីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ**):

- ប្រវត្តិផ្ទាល់ខ្លួនរបស់ឪពុកម្តាយចិញ្ចឹម
- ស្ថេរភាពផ្លូវចិត្ត និង ទំនាក់ទំនងល្អរបស់ឪពុកម្តាយចិញ្ចឹម
- ឪពុកម្តាយចិញ្ចឹមមានលំនៅដ្ឋានសមរម្យ ហើយតំបន់រស់នៅមានសុវត្ថិភាព កុមារអាចទទួលបានការអប់រំគ្រប់គ្រាន់ និង ការថែទាំសុខភាពកុមារបានជិតដល់
- ឪពុកម្តាយចិញ្ចឹមមានលទ្ធភាពក្នុងការផ្តល់ការគាំទ្រផ្នែកសម្ភារៈ និង ផ្នែកផ្លូវចិត្តដល់កុមារ
- ឪពុកម្តាយចិញ្ចឹមមានបំណងពិតប្រាកដក្នុងការចិញ្ចឹមកូនសុំនោះឱ្យដូចគ្នាទៅនឹងកូនបង្កើតរបស់ខ្លួន និង
- អារម្មណ៍របស់កុមារផ្សេងទៀត (បើមាន) ដែលរស់នៅក្នុងគ្រួសារនោះ ។

ព្រមទាំងព័ត៌មានដែលបានកំណត់ដូចខាងលើនេះ តុលាការក៏ត្រូវគិតពិចារណាលើស្ថានភាពដែលឪពុកម្តាយចិញ្ចឹមបានធ្វើនៅក្នុង**អំឡុងពេលសាកល្បងចិញ្ចឹម** ដែលមានចែងក្នុងមាត្រា ១០១៣ នៃក្រមរដ្ឋប្បវេណីដើម្បីធានាឧត្តមប្រយោជន៍របស់កុមារដែរ ។

## ច. អំឡុងពេលសាកល្បងចិញ្ចឹម

**មាត្រា ១០១៣. អំឡុងពេលសាកល្បងចិញ្ចឹម**

[illegible]

## ឆ. នីតិវិធីតុលាការសម្រាប់ស្មុំកូនពេញលេញ

[ច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង]

មាត្រា ៣ វិសាលភាពនៃច្បាប់នេះ

១. [illegible]

២. [illegible]

៣. [illegible]

(តារាងឧបសម្ព័ន្ធផ្នែកទី៤ចំណុចទី៧)

ចំណុចដែលត្រូវសម្រេចសេចក្តី [illegible] ពាក្យសុំឱ្យបង្កើតស្មុំកូនពេញលេញដោយយោងតាមបញ្ញត្តិនៃមាត្រា ១០០៧ (ទម្រង់នៃការបង្កើតស្មុំកូនពេញលេញ) ។

មាត្រា ១០០៧ នៃក្រមរដ្ឋប្បវេណី ចែងថា ដើម្បីបង្កើតស្មុំកូនពេញលេញត្រូវមានៈ

(១) **ពាក្យសុំ** របស់បុគ្គលដែលនឹងក្លាយជាឪពុកម្តាយចិញ្ចឹម និង

(២) **ដីកាសម្រេច** របស់តុលាការ ដែលទទួលស្គាល់ស្មុំកូនពេញលេញនោះ ។

នីតិវិធីតុលាការសម្រាប់ស្មុំកូនពេញលេញដូចខាងលើនេះ ត្រូវស្របតាមបទបញ្ញត្តិនៅក្នុង **ច្បាប់ស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង**។ មាត្រា ៣ នៃច្បាប់នេះ មានចែងអំពីវិសាលភាពនៃច្បាប់នេះ ហើយបញ្ញត្តិថា តុលាការត្រូវសម្រេចសេចក្តីតាមបញ្ញត្តិនៃច្បាប់នេះ ចំពោះចំណុចដែលកំណត់ក្នុងផ្នែកនីមួយៗនៃតារាងឧបសម្ព័ន្ធ ។ ហើយផ្នែកទី៤ចំណុចទី៧នៃតារាងឧបសម្ព័ន្ធនោះ មានកំណត់អំពីពាក្យសុំឱ្យបង្កើតស្មុំកូនពេញលេញដោយយោងតាមបញ្ញត្តិនៃមាត្រា១០០៧ (ទម្រង់នៃការបង្កើតស្មុំកូនពេញលេញ) នៃក្រមរដ្ឋប្បវេណី។ ដូច្នេះ